A Brief Introduction to the Bible

# សៀវភៅណែនាំពីព្រះគម្ពីរ

ស្វែងរក • ប្រព្រឹត្តតាម • បង្ហាត់បង្រៀន

— អែសរ៉ា ៧:១០

និពន្ធដោយ៖ ឈាង បូរ៉ា



**សៀវភៅនេះរៀបរាប់ត្រួសៗលើកណ្ឌគម្ពីរនីមួយៗស្តីពីៈ**

- អ្នកនិពន្ធ
- ឆ្នាំនិពន្ធ
- ការសង្ខេប
- គម្រោងកណ្ឌគម្ពីរ
- សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
- ការអនុវត្ត
- រូបភាព

**ទីបន្ទាល់ពីប្រសិទ្ធភាពនៃសៀវភៅនេះៈ**

*"បន្ទាប់ពីខ្ញុំបាទបានពិនិត្យមើលសៀវភៅមួយក្បាលនេះដោយយកចិត្តទុកដាក់ ហើយចង់ស្វែងយល់ពីសេចក្តីបង្រៀន និងគោលបំណងនៃសៀវភៅនេះមក ខ្ញុំបាទយល់ឃើញថា វាពិតជាមានផលល្អច្រើនសម្រាប់រូបខ្ញុំដែលជាសិស្សសាលាព្រះគម្ពីរម្នាក់ ដោយសារវាមានរៀបរាប់ជាលក្ខណៈសង្ខេបត្រួសៗហើយក្តោបយកខ្លឹមសារចម្បងយ៉ាងច្បាស់លាស់ រួមជាមួយនឹងការអនុវត្តដែលជួយផ្តល់ជាគំនិតល្អៗដើម្បីឲ្យខ្ញុំកាន់តែអាចយល់ពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយជំរុញឲ្យខ្ញុំចង់តែស្វែងយល់បន្ថែមពីព្រះបន្ទូល។ ខ្ញុំសង្ឃឹមថា ពេលដែលលោកអ្នកអានសៀវភៅមួយក្បាលនេះ នោះវានឹងជំរុញឲ្យលោកអ្នកកាន់តែចង់អាន ចង់សិក្សាព្រះគម្ពីរបន្ថែមទៀត ដូចរូបខ្ញុំផងដែរ។ សូមព្រះប្រទានពរ!"*

– លោក ជួប ប៊ុនហាក់

សាឡុមកម្ពុជា
www.smcambodia.org

ACTION CAMBODIA
www.actioncambodia.org

ISBN 9789996385001
90000 >
9 789996 385001

A Brief Introduction to the Bible

# សៀវភៅណែនាំពី

# ព្រះគម្ពីរ

ស្វែងរក • ប្រព្រឹត្តតាម • បង្ហាត់បង្រៀន

— អែសរ៉ា ៧:១០

និពន្ធដោយ៖ ឈាង បូរ៉ា

រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា
Copyright © 2014 by Bora Chheang
ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ជួប ប៊ុនហាក់ និង កញ្ញា សុគន្ធ ចិន្តាមណី
រចនាអត្ថបទ៖ លោក វែល ណាថាន

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ឆ្នាំ ១៩៥៤ ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូល យើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់ សម្តេចសង្ឃរាជ ជួន ណាត។

ព្រមជាមួយនឹងការប្រើប្រាស់កម្មវិធីត្រួតពិនិត្យអក្ខរាវិរុទ្ធ និងវេយ្យាករណ៍ យូនីកូដខ្មែរ របស់ ស.ស.ឈ.ន.ក. – http://www.sbbic.org

ISBN 978-99963-850-0-1

អត្ថបទគម្ពីរទាំងអស់ © រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរសកល
ដកស្រង់ដោយមានការអនុញ្ញាត

អត្ថបទគម្ពីរទាំងអស់ដែលមានអក្សរជាសម្គាល់ គគខ មកពី ព្រះគម្ពីរគ្រីស្តបរិស័ទខ្មែរ © រក្សាសិទ្ធិដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត ដកស្រង់ដោយមានការអនុញ្ញាត

គ្រប់រូបភាពជាកម្មសិទ្ធិសាធារណៈ លើកលែងតែរូបភាពទូកធំនៅទំព័រ១៤ រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ Answers in Genesis — www.AnswersInGenesis.org

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំសូមអរព្រះគុណ និងថ្លែងអំណរគុណដល់៖
ព្រះជាម្ចាស់ ពីព្រោះទ្រង់បានជួយឲ្យខ្ញុំចេះភាសាខ្មែរឡើងវិញ។ កន្លែងធ្វើការរបស់ខ្ញុំ (Action Cambodia) ដែលបានអនុញ្ញាតឲ្យខ្ញុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីសរសេរសៀវភៅនេះ។ លោក ជួប ប៊ុនហាក់ និង លោកស្រី កង សុគន្ធរ័ត្ន, លោក ម៉ែន ជំនោ, លោក វ៉ែល ណាថាន, កញ្ញា សុគន្ធ ចិន្តាមណី, លោកគ្រូ ជឿន ជីវិចន្ធា និង លោកស្រី អ៊ែរិនសិន វន្នី ដែលបានជួយកែតម្រូវសៀវភៅនេះ។

ខ្ញុំមិនបានសរសេរសៀវភៅនេះដោយគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំទាំងស្រុងនោះទេ ប៉ុន្តែខ្ញុំបានមើលព្រះគម្ពីរ *New American Standard* និងសៀវភៅ *Know Your Bible: All 66 Books Explained* និពន្ធដោយលោក ប៉ុល ខានទ៍ (Paul Kent) ហើយនិងរំឭកមេរៀនចាស់ៗរបស់ខ្ញុំដែលខ្ញុំបានសិក្សាជាមួយនឹងសាស្ត្រាចារ្យ William Varner, Daniel Wong, Tom Halstead និង Abner Chou នៅមហាវិទ្យាល័យ The Master's College។ បន្ទាប់មកខ្ញុំក៏ប្រមូលគំនិតទាំងនោះមកចងក្រងឡើង ដើម្បីឲ្យក្លាយទៅជា **សៀវភៅណែនាំពីព្រះគម្ពីរ** នេះ។

ខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងជួយគ្រីស្ទបរិស័ទឲ្យកាន់តែស្រឡាញ់ព្រះបន្ទូល និងព្រះជាម្ចាស់ថែមទៀត ព្រមទាំងសរសើរព្រះជាម្ចាស់ដែលជាព្រះលើអស់ទាំងព្រះ ជាព្រះដែលបានប្រទានព្រះរាជបុត្រារបស់ទ្រង់ឲ្យមកសុគតលើឈើឆ្កាង ទទួលទីបញ្ចុះក្នុងផ្នូរ ហើយបីថ្ងៃក្រោយមកទ្រង់មានព្រះជន្មរស់ឡើងវិញ (១កូរិនថូស ១៥:៣-៤)។

# មាតិកា


បុព្វកថា . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩
លោកុប្បត្តិ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៣
និក្ខមនំ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៥
លេវីវិន័យ. . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៩
ជនគណនា . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២១
ចោទិយកថា. . . . . . . . . . . . . . . . . . . . . . . . . . . . . . ២៣
យ៉ូស្វេ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២៥
ពួកចៅហ្វាយ . . . . . . . . . . . . . . . . . . . . . . . . . . . . . ២៧
នាងរស់. . . . . . . . . . . . . . . . . . . . . . . . . . . . . . . ២៩
សាំយូអែល ទី១ . . . . . . . . . . . . . . . . . . . . . . . . . . . ៣១
សាំយូអែល ទី២ . . . . . . . . . . . . . . . . . . . . . . . . . . . ៣៣
ពង្សាវតារក្សត្រ ទី១ . . . . . . . . . . . . . . . . . . . . . . . . ៣៥
ពង្សាវតារក្សត្រ ទី២ . . . . . . . . . . . . . . . . . . . . . . . . ៣៧
របាក្សត្រ ទី១ . . . . . . . . . . . . . . . . . . . . . . . . . . . ៣៩
របាក្សត្រ ទី២ . . . . . . . . . . . . . . . . . . . . . . . . . . . ៤១
អែសរ៉ា . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៣
នេហេមា . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៥
នាងអេសធើរ . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៧
យ៉ូប . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៤៩
ទំនុកដំកើង . . . . . . . . . . . . . . . . . . . . . . . . . . . . ៥១
សុភាសិត . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៥
សាស្តា . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៥៩

បទចំរៀងសាឡូម៉ូន . . . . . . . . . . . . . . . . . . . . . . . . ៦១
អេសាយ . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៣
យេរេមា . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៥
បរិទេវ . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៧
អេសេគាល . . . . . . . . . . . . . . . . . . . . . . . . . . . . ៦៩
ដានីយ៉ែល . . . . . . . . . . . . . . . . . . . . . . . . . . . . ៧១
ហូសេ . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៥
យ៉ូអែល . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៧
អេម៉ុស . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៩
អូបាឌា . . . . . . . . . . . . . . . . . . . . . . . . . . . . . ៨១
យ៉ូណាស . . . . . . . . . . . . . . . . . . . . . . . . . . . . . ៨៣
មីកា . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៨៥
ណាហ៊ុម . . . . . . . . . . . . . . . . . . . . . . . . . . . . . ៨៧
ហាបាគុក . . . . . . . . . . . . . . . . . . . . . . . . . . . . ៨៩
សេផានា . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩១
ហាកាយ . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩៣
សាការី . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩៥
ម៉ាឡាគី . . . . . . . . . . . . . . . . . . . . . . . . . . . . ៩៧
ម៉ាថាយ . . . . . . . . . . . . . . . . . . . . . . . . . . . . ១០១
ម៉ាកុស . . . . . . . . . . . . . . . . . . . . . . . . . . . . ១០៥
លូកា . . . . . . . . . . . . . . . . . . . . . . . . . . . . . ១០៧
យ៉ូហាន . . . . . . . . . . . . . . . . . . . . . . . . . . . . ១០៩
កិច្ចការ . . . . . . . . . . . . . . . . . . . . . . . . . . . ១១១
រ៉ូម . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១១៣

កូរិនថូស ទី១ . . . . . . . . . . . . . . . . . . . . . . . . . . . . ១១៧
កូរិនថូស ទី២ . . . . . . . . . . . . . . . . . . . . . . . . . . . . ១១៩
កាឡាទី . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១២១
អេភេសូរ . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១២៣
ភីលីព . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១២៧
កូល៉ុស . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៣១
ថែស្សាឡូនីច ទី១ . . . . . . . . . . . . . . . . . . . . . . . . . ១៣៣
ថែស្សាឡូនីច ទី២ . . . . . . . . . . . . . . . . . . . . . . . . . ១៣៥
ធីម៉ូថេ ទី១ . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៣៧
ធីម៉ូថេ ទី២ . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៣៩
ទីតុស . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៤១
ភីលេម៉ូន . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៤៣
ហេព្រើរ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៤៥
យ៉ាកុប . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៤៧
ពេត្រុស ទី១ . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៤៩
ពេត្រុស ទី២ . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៥១
យ៉ូហាន ទី១ . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៥៣
យ៉ូហាន ទី២ . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៥៥
យ៉ូហាន ទី៣ . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៥៧
យូដាស . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៥៩
វិវរណៈ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៦១

# បុព្វកថា

សៀវភៅនេះជាសំណេរណែនាំកណ្ឌគម្ពីរនីមួយៗនៅក្នុងព្រះគម្ពីរទាំងមូល ហើយខ្ញុំបានបែងចែកការសង្ខេបនេះជាប្រាំពីរផ្នែកផ្សេងៗគ្នា ដើម្បីជួយឲ្យលោកអ្នកស្គាល់ព្រះគម្ពីរបានកាន់តែច្បាស់។ ផ្នែកទាំងប្រាំពីរនោះរួមមាន៖ អ្នកនិពន្ធ, ឆ្នាំនិពន្ធ, ការសង្ខេប, គម្រោងកណ្ឌគម្ពីរ, សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់, ការអនុវត្ត, ព្រមទាំងរូបភាព។ ខ្ញុំសង្ឃឹមថា ការអានសៀវភៅនេះ នឹងជំរុញឲ្យលោកអ្នកកាន់តែចង់អានព្រះគម្ពីរខ្លាំងថែមទៀត។

លោកអ្នកអាចថតចម្លងសៀវភៅនេះយកទៅប្រើប្រាស់បាន ដោយមិនចាំបាច់សុំការអនុញ្ញាតពីខ្ញុំទេ ប៉ុន្តែ ហាមលក់ និងសូមកុំប្តូរឈ្មោះអ្នកនិពន្ធដើម។ លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ http://cambodianchristianresources.com/bib

ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖ borachheang@gmail.com

ឈាង បូរ៉ា

# សញ្ញទស់

# លោកុប្បត្តិ

## អ្នកនិពន្ធ

លោក ម៉ូសេ គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ម៉ាថាយ ១៩:៣-៩ និង ម៉ាកុស ១០:១-៩ បានបញ្ជាក់ថាលោក ម៉ូសេ បានសរសេរ “ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធ»។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ១៤៤៦-១៤០៦ មុន គ.ស នៅពេលដែលសាសន៍អ៊ីស្រាអែលវង្វេងនៅក្នុងទីរហោស្ថាន។

## ការសង្ខេប

ព្រះជាម្ចាស់បានបង្កើតផ្ទៃមេឃ និងផែនដី ហើយបានជ្រើសរើសសាសន៍អ៊ីស្រាអែលតាមរយៈលោក អ័ប្រាហាំ ឲ្យមកធ្វើជារាស្ត្ររបស់ទ្រង់ ដែលនឹងទទួលទឹកដីសន្យា។

## គម្រោងកណ្ឌគម្ពីរ

I. មានព្រឹត្តិការណ៍ដ៏អស្ចារ្យបួនយ៉ាង ជំពូក ១-១១

II. មានបុគ្គលដ៏អស្ចារ្យបួននាក់ ជំពូក ១២-៥០

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

លោកុប្បត្តិ ៣:១៥ “អញនឹងធ្វើឲ្យឯងហើយនិងស្ត្រី គឺទាំងពូជឯងនិងពូជនាងមានសេចក្តីខ្មាំងនឹងគ្នា ពូជនាងនឹងកិនក្បាលឯង ហើយឯង



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

នឹងចឹកកែងជើងគេ»។

លោកុប្បត្តិ ១៥:៦ «គាត់ក៏ជឿដល់ព្រះយេហូវ៉ា ហើយទ្រង់រាប់សេចក្ដីជំនឿនោះ ទុកជាសេចក្ដីសុចរិតដល់គាត់»។

លោកុប្បត្តិ ៥០:២០ «អ្នករាល់គ្នាបានគិតធ្វើអាក្រក់ដល់ខ្ញុំ តែព្រះទ្រង់សំរេចជាការល្អវិញ ដើម្បីនឹងសង្គ្រោះដល់ជីវិតនៃមនុស្សជាច្រើន ដូចជាបានកើតមានសព្វថ្ងៃនេះ»។

## ការអនុវត្ត

ចូរកោតខ្លាច ហើយទុកចិត្តលើព្រះជាម្ចាស់ ពីព្រោះទ្រង់គឺជាព្រះអាទិករដ៏ល្អ ហើយទ្រង់គ្រប់គ្រងលើអ្វីៗទាំងអស់ ។

## រូបភាព



ទូកធំ - លោកុប្បត្តិ ៦:១៤



សត្វចៀម - លោកុប្បត្តិ ១២:១៦



អាសនា - លោកុប្បត្តិ ៨:២០



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៊ូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# និក្ខមនំ

## អ្នកនិពន្ធ

លោក ម៉ូសេ គឺជាអ្នកនិពន្ធ ពីព្រោះនៅក្នុងកណ្ឌគម្ពីរ និក្ខមនំ ៣៤:២៧ បានចែងថា «រួចព្រះយេហូវ៉ាទ្រង់បង្គាប់ដល់ម៉ូសេថា ចូរកត់ពាក្យទាំងនេះចុះ...» ហើយព្រះយេស៊ូវបានហៅគម្ពីរនេះថា «គម្ពីររបស់លោក ម៉ូសេ» (ម៉ាកុស ១២:២៦)។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ១៤៤៦-១៤០៦ មុន គ.ស នៅពេលដែលសាសន៍អ៊ីស្រាអែល វង្វេងនៅក្នុងទីរហោស្ថាន។

## ការសង្ខេប

ព្រះជាម្ចាស់បានរំដោះសាសន៍អ៊ីស្រាអែលដែលជារាស្ត្ររបស់ទ្រង់ឲ្យរួចពីទាសភាពរបស់ប្រទេសអេស៊ីព្ទ ហើយទ្រង់បានតាំងសញ្ញាជាមួយពួកគេនៅភ្នំស៊ីណាយ។

## គម្រោងកណ្ឌគម្ពីរ

I. ការរៀបចំរបស់ព្រះជាម្ចាស់ ដើម្បីរំដោះសាសន៍អ៊ីស្រាអែលចេញពីភាពជាទាសករ ជំពូក ១-៤

II. ការរំដោះសាសន៍អ៊ីស្រាអែលចេញពីភាពជាទាសករ ជំពូក ៥-១៨

III. ការតាំងសញ្ញានៅភ្នំស៊ីណាយ ជំពូក ១៩-២៤

IV. គម្រោងសាងសង់រោងឧបោសថទុកសម្រាប់ថ្វាយបង្គំព្រះជាម្ចាស់ ជំពូក ២៥-៤០



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

និក្ខមនំ ៣:១៤ "ព្រះទ្រង់មានបន្ទូលទៅម៉ូសេថា "អញជាព្រះដ៏ជាព្រះ" រួចទ្រង់មានបន្ទូលទៀតថា ឯងត្រូវឆ្លើយប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលដូច្នេះថា ព្រះដ៏ជាព្រះទ្រង់បានចាត់ឲ្យខ្ញុំមកឯអ្នករាល់គ្នា"។

និក្ខមនំ ២០:៣ "កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ"។

## ការអនុវត្ត

ចូរទូលសូមជំនួយពីព្រះជាម្ចាស់នៅពេលដែលលោកអ្នកជួបទុក្ខលំបាក ដូចសាសន៍អ៊ីស្រាអែលបានទូលសូមទ្រង់ ហើយទ្រង់ក៏បានជួយពួកគេផងដែរ។

## រូបភាព


ចង្កៀង៧ - និក្ខមនំ ២៥:៣៧


អាសនាលង្ហិន - និក្ខមនំ ៣៩:៣៩


រោងឧបោសថ - និក្ខមនំ ២៥:៩



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## សំលៀកបំពាក់របស់សម្ដេចសង្ឃ - និក្ខមនំ ២៨:៤




**១**) មួក **២**) ប្រដាប់បាំងទ្រូង ជាមួយនឹងយូរីមនិងធូមីម
**៣**) ខ្សែក្រវាត់ **៤**) អេផូឌ



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# លេវីវិន័យ

## អ្នកនិពន្ធ
ប្រពៃណីអ៊ីស្រាអែលសន្មតថា លោក ម៉ូសេ គឺជាអ្នកនិពន្ធ ហើយ ព្រះយេស៊ូវបានហៅគម្ពីរនេះថា «គម្ពីររបស់លោក ម៉ូសេ» (ម៉ាកុស ១២:២៦)។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ១៤៤៦-១៤០៦ មុន គ.ស នៅពេលដែលសាសន៍ អ៊ីស្រាអែល វង្វេងនៅក្នុងទីរហោស្ថាន។

## ការសង្ខេប
ព្រះជាម្ចាស់ដែលជាព្រះដ៏បរិសុទ្ធបានបង្រៀនរាស្ត្ររបស់ទ្រង់ពីរបៀប ដែលពួកគេត្រូវថ្វាយបង្គំទ្រង់ ដើម្បីឲ្យពួកគេអាចប្រកបជាមួយទ្រង់។

## គម្រោងកណ្ឌគម្ពីរ
I. ផ្លូវ ជំពូក ១-១០

II. ការដើរ ជំពូក ១១-២០

III. ការថ្វាយបង្គំ ជំពូក ២១-២៤

IV. ការធ្វើបន្ទាល់ ជំពូក ២៥-២៧



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

លេវីវិន័យ ១១:៤៤ «ដ្បិតអញនេះ គឺព្រះយេហូវ៉ាជាព្រះនៃឯងរាល់គ្នា ដូច្នេះចូរឲ្យឯងរាល់គ្នាញែកខ្លួនចេញ ហើយឲ្យនៅជាបរិសុទ្ធចុះ ដ្បិតអញជាបរិសុទ្ធ មិនត្រូវឲ្យឯងរាល់គ្នានាំខ្លួនឲ្យទៅជាមិនស្អាត ដោយសារសត្វណាដែលលូនវារនៅដីឡើយ»។

លេវីវិន័យ ១៧:១១ «ដ្បិតជីវិតនៃរូបសាច់ នោះនៅក្នុងឈាម ហើយអញបានឲ្យឈាមដល់ឯងរាល់គ្នា សំរាប់នឹងថ្វាយនៅលើអាសនា ដើម្បីឲ្យបានធួននឹងជីវិតឯង ដ្បិតគឺជាឈាមនោះឯងដែលធួននឹងព្រលឹងបាន»។

## ការអនុវត្ត

យើងត្រូវរស់នៅឲ្យមានភាពបរិសុទ្ធ ដើម្បីឲ្យយើងអាចប្រកបជាមួយនឹងព្រះដ៏បរិសុទ្ធ។

## រូបភាព



មែកហ៊ីសុប - លេវីវិន័យ ១៤:៤



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# ជនគណនា

## អ្នកនិពន្ធ
ប្រពៃណីអ៊ីស្រាអែលសន្មតថា លោក ម៉ូសេ ជាអ្នកនិពន្ធ ហើយព្រះយេស៊ូវក៏បានមានបន្ទូលនៅក្នុងកណ្ឌគម្ពីរ លូកា ២៤:៤៤ ថា «...ត្រូវតែសម្រេចគ្រប់ទាំងសេចក្តីដែលបានចែងទុកពីខ្ញុំ ទោះក្នុងក្រឹត្យវិន័យលោកម៉ូសេ...»។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ១៤៤៦-១៤០៦ មុន គ.ស នៅពេលដែលសាសន៍អ៊ីស្រាអែលវង្វេងនៅក្នុងទីរហោស្ថាន។

## ការសង្ខេប
ដោយសារសាសន៍អ៊ីស្រាអែលមិនស្តាប់បង្គាប់ ហើយមិនជឿទុកចិត្តដល់ព្រះជាម្ចាស់ ហេតុដូច្នេះហើយបានជាពួកគេវង្វេងនៅក្នុងទីរហោស្ថានអស់រយៈពេល៤០ឆ្នាំ។

## គម្រោងកណ្ឌគម្ពីរ
I. ការធ្វើដំណើរនៅឯភ្នំស៊ីណាយ ជំពូក ១-១០
II. ការធ្វើដំណើរនៅឯទីរហោស្ថាន ជំពូក ១១-២៥
III. ការធ្វើដំណើរនៅឯប្រទេសវាលរបស់ម៉ូអាប់ ជំពូក ២៦-៣៦



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## សំណេរីខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ជនគណនា ១៤:១៨ “ព្រះយេហូវ៉ាទ្រង់យឺតនឹងខ្ញាល់ ក៏មាន សេចក្តីមេត្តាករុណាជាបរិបូរ ទ្រង់តែងអត់ទោសនៃសេចក្តីទុច្ចរិត នឹង ការរំលង តែមិនមែនរាប់មនុស្សមានទោស ទុកជាគ្មាននោះឡើយ គឺ ទ្រង់តែងធ្វើទោសនៃការទុច្ចរិតរបស់ឪពុកទៅដល់កូនចៅទាំង៣ដំណ ហើយ៤ដំណផង”។

## ការអនុវត្ត

ចូរស្តាប់បង្គាប់ ហើយជឿលើព្រះជាម្ចាស់ពីព្រោះ “…ទ្រង់យឺតនឹង ខ្ញាល់ ក៏មានសេចក្តីមេត្តាករុណាជាបរិបូរ ទ្រង់តែងអត់ទោសនៃ សេចក្តីទុច្ចរិត…” (ជនគណនា ១៤:១៨)។

## រូបភាព



ហឹបនៃសេចក្តីសញ្ញា - ជនគណនា ១០:៣៣



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ចោទិយកថា

## អ្នកនិពន្ធ

ប្រពៃណីអ៊ីស្រាអែលសន្មតថា លោក ម៉ូសេ គឺជាអ្នកនិពន្ធ ពីព្រោះ កណ្ឌគម្ពីរ ចោទិយកថា ៣១:៩ ចែងថា “ម៉ូសេក៏កត់ក្រឹត្យវិន័យនេះ ប្រគល់ឲ្យដល់ពួកសង្ឃ ជាកូនចៅលេវីដែលគេសែងហឹបនៃសេចក្តីសញ្ញាផងព្រះយេហូវ៉ា ហើយដល់ពួកចាស់ទុំនៃសាសន៍អ៊ីស្រាអែលទាំងប៉ុន្មានផង»។ លោក យ៉ូស្វេ ប្រហែលជាអ្នកនិពន្ធជំពូក៣៤ ដែលរៀបរាប់អំពីការស្លាប់របស់លោក ម៉ូសេ។

## ឆ្នាំនិពន្ធ

ប្រហែលនៅក្នុងឆ្នាំ ១៤០៦ មុន គ.ស មុនពេល លោក ម៉ូសេស្លាប់។

## ការសង្ខេប

លោក ម៉ូសេ រំឭកសាសន៍អ៊ីស្រាអែលឲ្យស្មោះត្រង់ចំពោះព្រះជាម្ចាស់។

## គម្រោងកណ្ឌគម្ពីរ

I. ការក្រឡេកមើលទៅអតីតកាល ជំពូក ១-១១

II. ការសម្លឹងមើលទៅអនាគតកាល ជំពូក ១២-៣២

III. ការសម្លឹងមើលទៅព្រះជាម្ចាស់ ជំពូក ៣៣-៣៤



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ចោទិយកថា ៦:៤ «ចូរស្តាប់ចុះ ឱអ៊ីស្រាអែលអើយ ព្រះយេហូវ៉ាជាព្រះនៃយើង គឺព្រះយេហូវ៉ាតែ១អង្គទ្រង់»។

ចោទិយកថា ៦:៥ «ត្រូវឲ្យឯងស្រឡាញ់ព្រះយេហូវ៉ា ជាព្រះនៃឯងឲ្យអស់ពីចិត្ត អស់ពីព្រលឹង ហើយអស់ពីកំឡាំងឯង»។

ចោទិយកថា ៦:១៥ «ដ្បិតព្រះយេហូវ៉ា ជាព្រះនៃឯង ដែលទ្រង់គង់នៅកណ្តាលពួកឯង ទ្រង់ជាព្រះប្រចណ្ឌ ក្រែងសេចក្តីខ្ញាល់នៃព្រះយេហូវ៉ាជាព្រះនៃឯង បានក្តៅឡើងទាស់នឹងឯង រួចទ្រង់បំផ្លាញឯងរាល់គ្នាពីលើផែនដីនេះចេញទៅ»។

## ការអនុវត្ត

ចូរសម្លឹងមើលទៅព្រះជាម្ចាស់ដោយស្មោះត្រង់ ហើយស្រឡាញ់ទ្រង់ឲ្យអស់ពីចិត្ត អស់ពីព្រលឹង និងអស់ពីកម្លាំង (ចោទិយកថា ៦:៣)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# យ៉ូស្វេ

## អ្នកនិពន្ធ
ប្រពៃណីអ៊ីស្រាអែលសន្មតថា លោក យ៉ូស្វេ គឺជាអ្នកនិពន្ធ លើកលែងតែប្រាំខចុងក្រោយនៃកណ្ឌគម្ពីរនេះតែប៉ុណ្ណោះ គឺនៅក្នុងជំពូក ២៤:២៩-៣៣ ដែលរៀបរាប់ពីសេចក្តីស្លាប់របស់គាត់។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ១៤០៥-១៣៧៤ មុន គ.ស។

## ការសង្ខេប
សាសន៍អ៊ីស្រាអែលបានវាយយកទឹកដីដែលព្រះជាម្ចាស់បានសន្យាឲ្យពួកគេ ហើយពួកគេក៏ចាប់ផ្តើមរស់នៅទីនោះ។

## គម្រោងកណ្ឌគម្ពីរ
I. ការវាយយកទឹកដីសន្យា ជំពូក ១-១២
II. ការចែកទឹកដីសន្យា ជំពូក ១៣-២៤

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
យ៉ូស្វេ ១:៩ «តើអញមិនបានបង្គាប់ឯងទេឬអី ដូច្នេះចូរឲ្យមានកំឡាំង និងចិត្តក្លាហានចុះ កុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុតចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជាមួយនៅកន្លែងណា ដែលឯងទៅផង»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

យ៉ូស្វេ ២៤:១៥ «...តែឯអញនិងពួកគ្រួអញ យើងទាំងអស់គ្នានឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ»។

## ការអនុវត្ត

ចូររំពឹងចាំទទួលសេចក្តីសន្យារបស់ព្រះជាម្ចាស់ដែលមាននៅក្នុងព្រះគម្ពីរ។

## រូបភាព



ត្រែស្នែងចៀម - យ៉ូស្វេ ៦:៤



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ពួកចៅហ្វាយ

## អ្នកនិពន្ធ
ប្រពៃណីអ៊ីស្រាអែលសន្មតថាហោរា សាំយូអែល គឺជាអ្នកនិពន្ធ ប៉ុន្តែព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ
ប្រហែលក្រោយឆ្នាំ ១000 មុន គ.ស។

## ការសង្ខេប
សាសន៍អ៊ីស្រាអែលធ្លាក់ទៅក្នុងអំពើបាប ជួបទុក្ខលំបាក ហើយបានទទួលការសង្គ្រោះម្តងហើយម្តងទៀតពីព្រះជាម្ចាស់។

## គម្រោងកណ្ឌគម្ពីរ
I. ការមិនស្តាប់បង្គាប់របស់សាសន៍អ៊ីស្រាអែល ជំពូក ១-៣
II. ការសង្គ្រោះសាសន៍អ៊ីស្រាអែល ជំពូក ៣-១៦
III. ទុក្ខលំបាករបស់សាសន៍អ៊ីស្រាអែល ជំពូក ១៧-២១

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
ពួកចៅហ្វាយ ២:១២ «គេបានបោះបង់ចោលព្រះយេហូវ៉ា ជាព្រះនៃពួកឰយុកោគេ ដែលទ្រង់បាននាំគេចេញពីស្រុកអេស៊ីព្ទមក បែរទៅតាមព្រះដទៃ ក្នុងពួកព្រះរបស់សាសន៍ទាំងប៉ុន្មាន ដែលនៅជុំវិញគេ ព្រមទាំងក្រាបថ្វាយបង្គំដល់ព្រះទាំងនោះផង ហើយបានបណ្តាលឲ្យព្រះយេហូវ៉ាមានសេចក្តីខ្ញាល់»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

ពួកចៅហ្វាយ ២:១៦ “ព្រះយេហូវ៉ាទ្រង់តាំងឲ្យមានពួកចៅហ្វាយ ដែលបានជួយសង្គ្រោះគេ ឲ្យរួចពីកណ្តាប់ដៃនៃពួកអ្នកដែល បំផ្លាញគេ”។

ពួកចៅហ្វាយ ៧:២ “ព្រះយេហូវ៉ាទ្រង់មានបន្ទូលទៅគេឌានថា ចំនួន មនុស្សដែលនៅជាមួយនឹងឯង មានគ្នាច្រើនពេកណាស់ នឹងឲ្យ អញប្រគល់ពួកម៉ាឌានមក ក្នុងកណ្តាប់ដៃគេ មិនបានឡើយ ក្រែង ពួកអ៊ីស្រាអែលអួតខ្លួន ទាស់នឹងអញវិញដោយថា អញបានជួយ សង្គ្រោះខ្លួនអញទេ”។

## ការអនុវត្ត

ចូរកុំធ្វើខុសដូចសាសន៍អ៊ីស្រាអែលដែល “...តែងតែប្រព្រឹត្តការ ដែលខ្លួនគិតឃើញថាត្រឹមត្រូវ” ប៉ុន្តែចូរស្តាប់តាមព្រះជាម្ចាស់វិញ (ពួកចៅហ្វាយ ១៧:៦)។

## រូបភាព



រូបនៃព្រះបាល - ពួកចៅហ្វាយ ២:១១



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូវ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# នាហ៊ុម

## អ្នកនិពន្ធ
ប្រពៃណីអ៊ីស្រាអែលសន្មតថាហោរា សាំយូអែល គឺជាអ្នកនិពន្ធ ប៉ុន្តែព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ
ប្រហែលក្រោយឆ្នាំ ១000 មុន គ.ស។

## ការសង្ខេប
សូម្បីតែសាសន៍អ៊ីស្រាអែលដែលកំពុងធ្លាក់ទៅក្នុងអំពើបាប ហើយពោរពេញទៅដោយអំពើពុករលួយក៏ដោយ ក៏ព្រះជាម្ចាស់នៅតែស្មោះត្រង់ចំពោះពួកគេ។

## គម្រោងកណ្ឌគម្ពីរ
I. ការបាក់បែក ជំពូក ១
II. ការស្តារឡើងវិញ ជំពូក ២
III. ការស្រឡាញ់ ជំពូក ៣
IV. ការសង្គ្រោះ ជំពូក ៤



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.0
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

នាងរស់ ១:១៦ “តែនាងឆ្លើយថា សូមកុំទទូចឲ្យខ្ញុំទៅចោលអ្នកម្ដាយ នឹងវិលទៅវិញ លែងតាមអ្នកម្ដាយនោះឡើយ ដ្បិតកន្លែងណាដែលអ្នកម្ដាយអញ្ជើញទៅ នោះខ្ញុំនឹងទៅតាម ហើយកន្លែងដែលអ្នកម្ដាយស្នាក់នៅ នោះខ្ញុំក៏នឹងនៅដែរ សាសន៍របស់អ្នកម្ដាយនឹងបានជាសាសន៍របស់ខ្ញុំ ហើយព្រះរបស់អ្នកម្ដាយនឹងបានជាព្រះរបស់ខ្ញុំដែរ»។

## ការអនុវត្ត

ចូរស្រឡាញ់ព្រះជាម្ចាស់ ដូចនាងរស់ស្រឡាញ់ម្ដាយក្មេករបស់នាង ដោយគ្មានលក្ខខណ្ឌ។

## រូបភាព



ស្រូវឱក - នាងរស់ ១:២២



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូ | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# សាំយូអែល ទី១

## អ្នកនិពន្ធ

ព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ១១០០-១០១០ មុន គ.ស។

## ការសង្ខេប

ព្រះជាម្ចាស់បានតែងតាំងឲ្យមានស្តេចសោយរាជ្យលើសាសន៍
អ៊ីស្រាអែលទាំងមូល។

## គម្រោងកណ្ឌគម្ពីរ

I. ការរៀបចំទទួលស្តេច ជំពូក ១-៩

II. ពេលវេលាដែលស្តេចសោយរាជ្យ ជំពូក ១០-៣១

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

១សាំយូអែល ១៦:៧ «តែព្រះយេហូវ៉ាទ្រង់មានបន្ទូលថា កុំឲ្យមើលតែឫកពាខាងក្រៅ ឬកំពស់ខ្លួននោះឡើយ ដ្បិតអញមិនទទួលអ្នកនេះទេ ពីព្រោះព្រះទ្រង់មិនទតចំពោះសេចក្តី ដែលមនុស្សលោកពិចារណាមើលទេ ឯមនុស្សលោក តែងមើលតែឫកពាខាងក្រៅប៉ុណ្ណោះ តែព្រះយេហូវ៉ាទ្រង់ទតចំពោះក្នុងចិត្តវិញ»។

## ការអនុវត្ត

កុំប្រព្រឹត្តតាមតែបំណងចិត្តរបស់ខ្លួនឯង ដូចស្តេច សូល ប៉ុន្តែចូរស្តាប់បង្គាប់ព្រះជាម្ចាស់វិញ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# រូបភាព



ខ្សែដង្ហក់ - ១សាំយូអែល ១៧:៥០



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# សាំយូអែល ទី២

## អ្នកនិពន្ធ

ព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ១០១០-៩៧០ មុន គ.ស ពេលដែលស្ដេច ដាវីឌ សោយរាជ្យ។

## ការសង្ខេប

ការសោយរាជ្យរបស់ស្ដេច ដាវីឌ។

## គម្រោងកណ្ឌគម្ពីរ

I. ជ័យជម្នះរបស់ស្ដេច ដាវីឌ ជំពូក ១-១០
II. ការប្រព្រឹត្តរំលងរបស់ស្ដេច ដាវីឌ ជំពូក ១១-១២
III. បញ្ហារបស់ស្ដេច ដាវីឌ ជំពូក ១៣-២៤

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

២សាំយូអែល ៧:១៦ «នោះវង្សា និងរាជ្យរបស់ឯងនឹងបានតាំងជាប់នៅចំពោះឯង ជាដរាបតទៅ បល្ល័ង្កឯងនឹងបានខ្ជាប់ខ្ជួននៅ ជារៀងរាបដរាបទៅ»។

២សាំយូអែល ១២:២៣ «តែឥឡូវនេះបុត្រសុគតទៅហើយ ដូច្នេះតើយើងនៅតមអត់ធ្វើអ្វីទៀត តើយើងអាចនឹងនាំបុត្រឲ្យត្រឡប់មកវិញបានដែរឬ យើងនឹងទៅឯវា តែវាមិនដែលត្រឡប់មកឯយើងវិញឡើយ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

២សាំយូអែល ២៤:២៤ “តែស្ដេចមានបន្ទូលទៅអ័រ៉ោណាថា កុំឡើយ គឺយើងចង់ទិញពីឯងតាមដំឡៃវិញ យើងមិនព្រមយករបស់ ដែលយើងមិនបានចេញថ្លៃទិញ ទៅថ្វាយដល់ព្រះយេហូវ៉ាជាព្រះនៃយើងឡើយ ដូច្នេះដាវីឌក៏ទិញលានស្រូវ និងគោទាំងនោះ ដំឡៃជាប្រាក់៥០ រៀល”។

## ការអនុវត្ត

ក្នុងនាមជាអ្នកដឹកនាំ ចូរបន្ទាបខ្លួនដូចស្ដេច ដាវីឌ ដែលបានបន្ទាបអង្គទ្រង់ចំពោះព្រះជាម្ចាស់ដោយលន់តួបាបរបស់ទ្រង់ដល់ព្រះជាម្ចាស់ក្រោយពេលដែលហោរា ណាថាន់ បានប្រាប់ថាទ្រង់បានប្រព្រឹត្តបាបទាស់នឹងព្រះជាម្ចាស់។

## រូបភាព



ខែលនិងដាវ - ២សាំយូអែល ១:២១



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# ពង្សាវតារក្សត្រ ទី១

## អ្នកនិពន្ធ

ប្រពៃណីអ៊ីស្រាអែលសន្មតថាហោរា យេរេមា គឺជាអ្នកនិពន្ធ ប៉ុន្តែព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ

ប្រហែលជាក្រោយឆ្នាំ ៥៦២ មុន គ.ស នៅក្នុងអំឡុងពេលស្ដេចយ៉ូយ៉ាគីន ចេញពីគុក ឬក៏មុនឆ្នាំ ៥៣៨ មុន គ.ស នៅពេលដែលសាសន៍អ៊ីស្រាអែលជាប់ជាឈ្លើយរបស់ប្រទេសបាប៊ីឡូន។

## ការសង្ខេប

ប្រទេសអ៊ីស្រាអែលបានបែកជាពីរ៖ អ៊ីស្រាអែលខាងជើង និងអ៊ីស្រាអែលខាងត្បូង ហើយពួកគេបានក្លាយជាឈ្លើយរបស់ប្រទេសដទៃ ដូចជាពាក្យទំនាយ ដោយសារតែពួកគេមិនស្ដាប់បង្គាប់ព្រះ។

## គម្រោងកណ្ឌគម្ពីរ

I. នគររួបរួម (ស្ដេច សាឡូម៉ូន) ជំពូក ១-១១
II. នគរបាក់បែក (ស្ដេចជាច្រើន) ជំពូក ១២-២២

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

១ពង្សាវតារក្សត្រ ១៨:៣៧ «សូមស្ដាប់ទូលបង្គំ ឱព្រះយេហូវ៉ាអើយ សូមស្ដាប់ទូលបង្គំ ដើម្បីឲ្យប្រជាជននេះបានដឹងថា គឺទ្រង់ឱព្រះយេហូវ៉ាអើយ ដែលជាព្រះ ហើយថា គឺទ្រង់ដែលនាំចិត្តគេត្រឡប់មកវិញ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរទូលសូមប្រាជ្ញាពីព្រះជាម្ចាស់ក្នុងការរស់នៅរបស់លោកអ្នកដូច ស្ដេច សាឡូម៉ូន បានទូលសូមដើម្បីដឹកនាំរាស្ដ្ររបស់ទ្រង់។

## រូបភាព



ព្រះវិហារនៃព្រះយេហូវ៉ា - ១ពង្សាវតារក្សត្រ ៩:១



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ពង្សាវតារក្សត្រ ទី២

## អ្នកនិពន្ធ
ដូចគ្នានឹងកណ្ឌគម្ពីរ១ពង្សាវតារក្សត្រប្រពៃណីអ៊ីស្រាអែលសន្មតថា ហោរា យេរេមា គឺជាអ្នកនិពន្ធកណ្ឌគម្ពីរ២ពង្សាវតារក្សត្រ ប៉ុន្តែព្រះគម្ពីរមិនបានបញ្ជាក់ថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ
ដូចគ្នានឹងកណ្ឌគម្ពីរ១ពង្សាវតារក្សត្រប្រហែលក្រោយឆ្នាំ ៥៦២ មុន គ.ស នៅពេលដែលស្តេច យ៉ូយ៉ាគីន ចេញពីគុក ឬមុនឆ្នាំ ៥៣៨ មុន គ.ស នៅពេលដែលសាសន៍អ៊ីស្រាអែលជាប់ជាឈ្លើយរបស់ប្រទេសបាប៊ីឡូន។

## ការសង្ខេប
ដោយសារអ៊ីស្រាអែលខាងជើង និងខាងត្បូងមិនស្តាប់បង្គាប់ព្រះជាម្ចាស់ បានជាទ្រង់បំផ្លាញប្រទេសរបស់ពួកគេ។

## គម្រោងកណ្ឌគម្ពីរ
I. នគរបាក់បែក (អ៊ីស្រាអែលដួលរលំ) ជំពូក ១-១៧

II. នគរដែលមិនទាន់បាក់បែក (យូដាដួលរលំ) ជំពូក ១៨-២៥

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
២ពង្សាវតារក្សត្រ ២:១១ «រួចកំពុងដែលអ្នកទាំង២ដើរទៅ ហើយនិយាយគ្នាទៀត នោះស្រាប់តែឃើញរថជាភ្លើង និងសេះជាភ្លើង មកញែកលោកចេញពីគ្នា ហើយអេលីយ៉ាក៏ឡើងទៅឯស្ថានសួគ៌ ដោយខ្យល់កួច»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

២ពង្សាវតារក្សត្រ ១៧:២០ «ហេតុនោះបានជាព្រះយេហូវ៉ា ទ្រង់បោះបង់ចោលពូជអ៊ីស្រាអែលទាំងអស់ក៏ធ្វើទុក្ខគេ ហើយប្រគល់គេទៅក្នុងកណ្តាប់ដៃរបស់ពួកអ្នកដែលបំផ្លាញគេ ដរាបដល់ទ្រង់បានបោះគេចោល ពីចំពោះព្រះភក្ត្រទ្រង់ចេញ»។

២ពង្សាវតារក្សត្រ ២៥:២១ «ស្តេចបាប៊ីឡូនក៏សំឡាប់អ្នកទាំងនោះនៅត្រង់រីបឡា ក្នុងស្រុកហាម៉ាតទៅ ដូច្នេះ ពួកយូដាត្រូវដឹកនាំទៅជាឈ្លើយ ក្រៅពីស្រុករបស់ខ្លួន»។

## ការអនុវត្ត

គំរូអាក្រក់ក៏មានប្រយោជន៍សម្រាប់យើងដែរ ប្រសិនបើយើងសម្រេចចិត្តថានឹងមិនធ្វើតាមគំរូអាក្រក់នោះ។

## រូបភាព



រថជាភ្លើងនិងសេះជាភ្លើង - ២ពង្សាវតារក្សត្រ ២:១១



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# របាក្សត្រ ទី១

## អ្នកនិពន្ធ

ប្រពៃណីអ៊ីស្រាអែលសន្មតថាហោរា អែសរ៉ា គឺជាអ្នកនិពន្ធកណ្ឌគម្ពីរ ១របាក្សត្រ ប៉ុន្តែព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៥៧០-៥៣៨ មុន គ.ស។

## ការសង្ខេប

កណ្ឌគម្ពីរនេះបានរៀបរាប់ ហើយវិភាគយ៉ាងល្អិតល្អន់អំពី ការសោយរាជ្យរបស់ស្តេច ដាវីឌ។

## គម្រោងកណ្ឌគម្ពីរ

I. ពង្សាវតាររបស់ស្តេច ដាវីឌ ជំពូក ១-៩

II. ការសោយរាជ្យដ៏ត្រឹមត្រូវរបស់ស្តេច ដាវីឌ ជំពូក ១០-២៩

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

១របាក្សត្រ ១៧:១៤ «គឺនឹងតាំងអ្នកនោះ នៅក្នុងព្រះវិហារ ហើយក្នុងនគររបស់អញឲ្យនៅជាដរាប ហើយរាជ្យអ្នកនោះនឹងបាននៅជាប់ ជារៀងរាបដរាបទៅ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរទុកចិត្តលើព្រះជាម្ចាស់ ដ្បិតទ្រង់ស្មោះត្រង់ ហើយក៏មិនដែលប្រែប្រួល ព្រមទាំងរក្សាពាក្យសន្យារបស់ទ្រង់ជានិច្ចផងដែរ ទោះបីជាយើងស្ថិតនៅក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយ។

## រូបភាព



ព្រះដាកុន - ១របាក្សត្រ ១០:១០



តុនំបុ័ងតាំងទុក - ១របាក្សត្រ ២៨:១៦



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូវ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# របាក្សត្រ ទី២

## អ្នកនិពន្ធ

ដូចគ្នានឹងកណ្ឌគម្ពីរ១របាក្សត្រផងដែរប្រពៃណីអ៊ីស្រាអែលសន្មតថា ហោរា អែសរ៉ា គឺជាអ្នកនិពន្ធកណ្ឌគម្ពីរ២របាក្សត្រនេះ ប៉ុន្តែព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៩៧០-៥៣៨ មុន គ.ស។

## ការសង្ខេប

កណ្ឌគម្ពីរនេះរៀបរាប់ពីប្រវត្តិសាស្រ្តរបស់ប្រទេសអ៊ីស្រាអែលដែលស្ថិតក្រោមការដឹកនាំរបស់ស្តេច សាឡូម៉ូន រហូតដល់ប្រទេសនេះមានការបែកបាក់ ហើយសាសន៍ដទៃទៀតបានវាយបំផ្លាញពួកគេ ប៉ុន្តែព្រះជាម្ចាស់បានរក្សាទុកកូនចៅយូដាខ្លះ ហើយខ្លះទៀតគេបានដឹកយកទៅធ្វើជាឈ្លើយ។

## គម្រោងកណ្ឌគម្ពីរ

I. ការសោយរាជ្យរបស់ស្តេច សាឡូម៉ូន ជំពូក ១-៩

II. ការសោយរាជ្យរបស់ស្តេចផ្សេងៗនៃសាសន៍យូដា ជំពូក ១០-៣៦



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូវ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

២របាក្សត្រ ៦:១៤ «ទូលថា ឱព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលអើយ គ្មានព្រះឯណាឲ្យដូចទ្រង់ឡើយ ទោះនៅលើមេឃ ឬនៅផែនដីក្តី ទ្រង់កាន់តាមសេចក្តីសញ្ញា និងសេចក្តីសប្បុរសដល់ពួកអ្នកបំរើទ្រង់ ដែលដើរនៅចំពោះទ្រង់ដោយចិត្តស្មោះត្រង់»។

## ការអនុវត្ត

ចូរចងចាំថា ការដែលព្រះជាម្ចាស់ដាក់ទោសលោកអ្នក គឺមិនមែនសម្រាប់ឲ្យលោកអ្នកមានការឈឺចាប់នោះទេ ប៉ុន្តែគឺដើម្បីរំឭកលោកអ្នកឲ្យត្រឡប់ទៅទ្រង់វិញ។

## រូបភាព



រទេះចម្បាំង - ២របាក្សត្រ ១:១៤



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# អែសរ៉ា

## អ្នកនិពន្ធ
ប្រពៃណីអ៊ីស្រាអែលសន្មតថាលោក អែសរ៉ា គឺជាអ្នកនិពន្ធកណ្ឌគម្ពីរ អែសរ៉ា ប៉ុន្តែព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ៥៣០-៤០០ មុន គ.ស។

## ការសង្ខេប
ក្រោយពេលដែលសាសន៍យូដាបានរួចផុតពីភាពជាឈ្លើយរបស់ប្រទេសពើស៊ី ពេលនោះពួកគេក៏ចាប់ផ្ដើមប្រែចិត្ត ហើយក៏ដើរតាមព្រះជាម្ចាស់វិញ។

## គម្រោងកណ្ឌគម្ពីរ
I. ការសាងសង់ព្រះវិហារឡើងវិញក្រោមការដឹកនាំរបស់លោក សូរ៉ូបាបិល ជំពូក ១-៦

II. ការស្ដារការថ្វាយបង្គំព្រះជាម្ចាស់ឡើងវិញក្រោមការដឹកនាំរបស់លោក អែសរ៉ា ជំពូក ៧-១០

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
អែសរ៉ា ៧:១០ «ពីព្រោះអែសរ៉ាបានតាំងចិត្តស្វែងរកក្នុងក្រឹត្យវិន័យរបស់ព្រះយេហូវ៉ា ដើម្បីនឹងប្រព្រឹត្តតាម ហើយបង្ហាត់បង្រៀនតាមបញ្ញត្ត និងសេចក្ដីយុត្តិធម៌ក្នុងពួកអ៊ីស្រាអែល»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរប្រែចិត្តហើយរស់នៅដោយបង្ហាញថា លោកអ្នកជាកូនរបស់ព្រះជាម្ចាស់ដោយដើរតាមទ្រង់ជានិច្ច។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# នេហេមា

## អ្នកនិពន្ធ

លោក នេហេមា គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ នេហេមា ១:១ បានចែងថា “នេះជាពាក្យរបស់នេហេមា ជាកូនហាកាលា...”។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៥៣០-៤០០ មុន គ.ស។

## ការសង្ខេប

បន្ទាប់ពីសាសន៍យូដារួចផុតពីភាពជាឈ្លើយរបស់ប្រទេសពើស៊ី នោះពួកគេក៏ចាប់ផ្ដើមកសាងកំផែងក្រុងយេរូសាឡិមដែលបាក់បែកឡើងវិញ។

## គម្រោងកណ្ឌគម្ពីរ

I. ការសាងសង់កំផែងក្រុងយេរូសាឡិមឡើងវិញ ជំពូក ១-១៣

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

នេហេមា ១:១១ “ឱព្រះអម្ចាស់អើយ សូមទ្រង់ផ្ទៀងព្រះកាណ៌ស្ដាប់ចំពោះសេចក្តីអធិស្ឋានរបស់ទូលបង្គំ និងសេចក្ដីអធិស្ឋានរបស់ពួកអ្នកបំរើទ្រង់ ដែលកោតខ្លាចដល់ព្រះនាមទ្រង់ ដោយអំណរ ហើយសូមចំរើនដល់ទូលបង្គំជាអ្នកបំរើទ្រង់ ដោយប្រោសប្រទានឲ្យមនុស្សនេះមានចិត្តមេត្តា ដល់ទូលបង្គំនៅថ្ងៃនេះ (រីឯខ្ញុំជាអ្នកថ្វាយពែងដល់ស្ដេច)”។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរចំណាយពេលអធិស្ឋានគ្រប់ពេលវេលាដូចលោក នេហេមា ដែល
បានចំណាយពេលអធិស្ឋានគ្រប់ពេលវេលាផងដែរ។

## រូបភាព



ស៊ុង - នេហេមា ១២:២៧



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# នាងអេសធើរ

## អ្នកនិពន្ធ
ប្រហែលជាលោក ម៉ាដេកាយ ឬលោក អែសរ៉ា ឬក៏នេហេមាជាអ្នកនិពន្ធ ប៉ុន្តែព្រះគម្ពីរមិនបានរៀបរាប់អ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ៤៨៦-៤៦៥ មុន គ.ស នៅពេលស្តេច អ័ហាស៊ូរុស សោយរាជ្យ។

## ការសង្ខេប
ស្ត្រីដ៏ស្រស់ស្អាតមួយរូបរបស់សាសន៍យូដាបានក្លាយទៅជាមហាក្សត្រីនៃសាសន៍ពើស៊ី ហើយក៏បានសង្គ្រោះប្រជារាស្ត្ររបស់នាង។

## គម្រោងកណ្ឌគម្ពីរ
I. ការគំរាមកំហែងដល់សាសន៍យូដា ជំពូក ១-៤
II. ជ័យជម្នះរបស់សាសន៍យូដា ជំពូក ៥-១០

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
នាងអេសធើរ ៤:១៤ «ដ្បិតបើព្រះនាងនឹងស្ងៀមនៅក្នុងវេលានេះ នោះនឹងកើតមានសេចក្តីសង្គ្រោះ និងសេចក្តីប្រោសឲ្យរួច ដល់ពួកយូដាពីកន្លែងផ្សេងទៀត តែព្រះនាង និងញាតិវង្សរបស់បិតានៃព្រះនាងនឹងត្រូវវិនាសវិញ ហើយប្រហែលជាព្រះនាង បានតាំងឡើងក្នុងរាជ្យសំរាប់ពេលនេះឯងទេដឹង»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរប្រើឋានៈ និងការងាររបស់លោកអ្នក ដើម្បីជួយអ្នកដទៃ។

## រូបភាព



ព្រះដំបងមាស - នាងអេសធើរ ៥:២



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# យ៉ូប

## អ្នកនិពន្ធ
ព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធកណ្ឌគម្ពីរ យ៉ូប នោះទេ។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ២000-១000 មុន គ.ស។

## ការសង្ខេប
ព្រះជាម្ចាស់នៅតែមានភាពយុត្តិធម៌ ទោះបីជាពេលខ្លះមនុស្សយើង
ជួបនឹងការឈឺចាប់ក៏ដោយ។

## គម្រោងកណ្ឌគម្ពីរ
I. ការរងទុក្ខរបស់លោក យ៉ូប ជំពូក ១-២
II. ការសន្ទនារបស់លោក យ៉ូប ជំពូក ៣-៣៧
III. ការជួយសង្គ្រោះលោក យ៉ូប ជំពូក ៣៨-៤២

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
យ៉ូប ១៩:២៥ «ប៉ុន្តែឯខ្ញុំៗដឹងថាអ្នកដែលលោះខ្ញុំទ្រង់មានព្រះជន្ម
រស់នៅ ហើយដល់ជាន់ក្រោយ ទ្រង់នឹងមកឈរនៅលើផែនដី»។

យ៉ូប ៣៣:២៨ «ប៉ុន្តែទ្រង់បានលោះព្រលឹងខ្ញុំមិនឲ្យធ្លាក់ទៅក្នុងរណ្ដៅ
ទេ ជីវិតខ្ញុំក៏នឹងឃើញពន្លឺដែរ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ព្រះជាម្ចាស់ គឺនៅតែជាព្រះដ៏ល្អ ទោះបីជាយើងជួបការរងទុក្ខយ៉ាងធំប៉ុណ្ណាក៏ដោយ ដូច្នេះចូរចុះចូល ហើយថ្វាយបង្គំព្រះជាម្ចាស់ គ្រប់កាលៈទេសៈ។

## រូបភាព



ដំរីទឹក* - យ៉ូប ៤០:១៥



ក្រពើ* - យ៉ូប ៤១:១

* មនុស្សមួយចំនួនបានទទួលស្គាល់ថា សត្វទាំងពីរនេះមិនមែនជាសត្វក្រពើ ឬដំរីទឹកនោះទេ ប៉ុន្តែប្រហែលជាសត្វដាយណូស័រវិញ។ យោងតាមការពន្យល់នៅក្នុងកណ្ឌគម្ពីរយ៉ូប សត្វទាំងពីរនេះមានលក្ខណៈខុសប្លែកពីសត្វក្រពើ និងដំរីទឹកដែលមាននៅសព្វថ្ងៃនេះ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.0
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# ទំនុកដំកើង

## អ្នកនិពន្ធ

មានអ្នកនិពន្ធជាច្រើនដូចជាស្តេច ដាវីឌ ស្តេច សាឡូម៉ូន លោក អេសាភ ពួកកូនលោក កូរេ លោក ម៉ូសេ លោក ហេម៉ាន និងលោក អេថាន ដែលជាពូជពង្សរបស់លោក អេសរ៉ាគីត។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ១៤០០-៥០០ មុន គ.ស។

## ការសង្ខេប

កណ្ឌគម្ពីរទំនុកដំកើង គឺជាសៀវភៅចម្រៀងមួយក្បាលរបស់សាសន៍យូដាដែលមានពេញទៅដោយ សេចក្តីអធិស្ឋាន ចម្រៀងសរសើរតម្កើង និងសេចក្តីទំនួញ។ល។

## គម្រោងកណ្ឌគម្ពីរ

I. សៀវភៅទី១ ជំពូក ១-៤១

II. សៀវភៅទី២ ជំពូក ៤២-៧២

III. សៀវភៅទី៣ ជំពូក ៧៣-៨៩

IV. សៀវភៅទី៤ ជំពូក ៩០-១០៦

V. សៀវភៅទី៥ ជំពូក ១០៧-១៥០



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ទំនុកដំកើង ៨:១ «ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់នៃយើងខ្ញុំអើយ ព្រះនាមទ្រង់ប្រសើរគ្រប់លើផែនដីយ៉ាងណាទៅ ទ្រង់បានដំកល់សិរីល្អទ្រង់ទុកនៅលើស្ថានសួគ៌»។

ទំនុកដំកើង ២៣:១ «ព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះ»។

ទំនុកដំកើង ៥១:១០ «ឱព្រះអង្គអើយ សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងទូលបង្គំ ហើយកែវិញ្ញាណក្នុងទូលបង្គំឲ្យត្រឹមត្រូវឡើង»។

ទំនុកដំកើង ១១៩:១១ «ទូលបង្គំបានកំណត់ចាំព្រះបន្ទូលទ្រង់ទុកនៅក្នុងចិត្ត ប្រយោជន៍កុំឲ្យទូលបង្គំធ្វើបាបនឹងទ្រង់ឡើយ»។

ទំនុកដំកើង ១២១:១-២ «ខ្ញុំនឹងងើបភ្នែកមើលទៅឯភ្នំ តែសេចក្ដីជំនួយជួយដល់ខ្ញុំមកពីណា សេចក្ដីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេ គឺជាព្រះដែលបង្កើតផ្ទៃមេឃ និងផែនដី»។

ទំនុកដំកើង ១៣៣:១ «មើល ដែលបងប្អូននៅមូលជាមួយគ្នា ដោយចិត្តព្រមព្រៀង នោះជាការល្អ ហើយសមគួរយ៉ាងណាទៅ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ដោយសារកណ្ឌគម្ពីរទំនុកដំកើងមានពេញទៅដោយពាក្យពេចន៍គ្រប់យ៉ាងទៅកាន់ព្រះជាម្ចាស់ ដូច្នេះយើងក៏អាចបញ្ចេញពាក្យពេចន៍បែបនេះទៅចំពោះព្រះជាម្ចាស់បានដែរ ដូចជានៅពេល ថ្វាយបង្គំ អធិស្ឋាន សរសើតម្កើង។ល។

## រូបភាព

**ឧបករណ៍ភ្លេង**




១) ស៊ុង - ទំនុកដំកើង ៣៣:២

២) ឈឹង - ទំនុកដំកើង ១៥០:៥

៣) ក្រាប់ - ទំនុកដំកើង ៦៨:២៥

៤) ស្នែង - ទំនុកដំកើង ៩៨:៦

៥) ពិណ - ទំនុកដំកើង ៣៣:២

៦) ត្រែ - ទំនុកដំកើង ៩៨:៦



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# សុភាសិត

## អ្នកនិពន្ធ
ស្ដេច សាឡូម៉ូន លោក អេគើរ និងស្ដេច លេមយូល គឺជាអ្នកនិពន្ធកណ្ឌគម្ពីរសុភាសិត។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ៩៧០-៩៣០ មុន គ.ស នៅពេលដែលស្ដេច សាឡូម៉ូន សោយរាជ្យ ហើយក្រោយមកទៀតស្ដេច ហេសេគា បានប្រើពួកស្មៀនរបស់ទ្រង់ឲ្យចម្លងទុក (សុភាសិត ២៥:១)។

## ការសង្ខេប
កណ្ឌគម្ពីរនេះលើកទឹកចិត្តយើងឲ្យចេះស្រឡាញ់ប្រាជ្ញា (១:១-៧)។

## គម្រោងកណ្ឌគម្ពីរ
I. សុភាសិតរបស់ស្ដេច សាឡូម៉ូន ជំពូក ១-២៩
II. សុភាសិតរបស់លោក អេគើរ ជំពូក ៣០
III. សុភាសិតរបស់ស្ដេច លេមយូល ជំពូក ៣១

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
សុភាសិត ១:៧ «សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃដំរិះ តែមនុស្សឥតបើគិត គេមើលងាយប្រាជ្ញា និងសេចក្ដីប្រៀនប្រដៅវិញ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

សុភាសិត ៣:៥-៦ «ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង»។

សុភាសិត ៦:៦-១១ «ឱមនុស្សខ្ជិលច្រអូសអើយ ចូរទៅមើលស្រមោចចុះ ចូរពិចារណាផ្លូវទាំងប៉ុន្មានរបស់វា ហើយមានប្រាជ្ញាឡើង វាគ្មាននាយ គ្មានអ្នកកាន់កាប់ការ ឬអ្នកគ្រប់គ្រងឡើយ គង់តែវាផ្គត់ផ្គង់អាហារវានៅខែប្រាំង ហើយក៏ប្រមូលស្បៀងទុក នៅក្នុងរដូវចំរូតផង ឱមនុស្សខ្ជិលច្រអូសអើយ តើឯងនឹងដេកដល់កាលណា តើដល់កាលណាបានឯងក្រោកពីការដេកលក់ ដេកបន្តិច ងោកបន្តិច ឱបដៃនឹងដេកបន្តិច យ៉ាងនោះ សេចក្តីកំសត់ទុគ៌តរបស់ឯង នឹងលោមកដល់ដូចជាចោរប្លន់ ព្រមទាំងសេចក្តីខ្វះខាត ដូចជាអ្នកកាន់គ្រឿងអាវុធ»។

សុភាសិត ១១:២២ «ស្រ្តីមានរូបស្រស់ល្អ ដែលឥតមានគំនិតមារយាទ នោះប្រៀបដូចជាក្រវិលមាសដែលពាក់នៅច្រមុះជ្រូក»។

សុភាសិត ១៣:២៤ «អ្នកណាដែលមិនសូវប្រើរំពាត់ នោះឈ្មោះថាស្អប់កូន តែអ្នកណាដែលស្រឡាញ់កូនវិញ នោះឧស្សាហ៍វាយផ្ចាលវា»។

សុភាសិត ១៥:១ «ពាក្យតបឆ្លើយដោយស្រទន់ នោះរមែងរំងាប់សេចក្តីក្រោធទៅ តែពាក្យគំរោះគំរើយ នោះបណ្តាលឲ្យមានសេចក្តីកំហឹងវិញ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

សុភាសិត ១៦:៣ «ចូរទុកដាក់អស់ទាំងការឯង នៅនឹងព្រះយេហូវ៉ាចុះ នោះអស់ទាំងគំនិតរបស់ឯងនឹងបានសំរេច»។

សុភាសិត ១៧:២៨ «សូម្បីតែមនុស្សឆ្កួត បើវានៅមាត់ស្ងៀម នោះគេរាប់ថាជាអ្នកមានប្រាជ្ញាដែរ ឯអ្នកណាដែលបិតបបូរមាត់ខ្លួនទុក នោះក៏រាប់ជាអ្នកឆ្លៀវឆ្លាតហើយ»។

សុភាសិត ១៨:១០ «ព្រះនាមព្រះយេហូវ៉ាជាប៉មមាំមួន មនុស្សសុចរិតរត់ចូលទៅពឹងជ្រក ហើយមានសេចក្ដីសុខ»។

សុភាសិត ២២:១ «នាមឈ្មោះល្អ នោះគួររើសយក ជាជាងទ្រព្យសម្បត្តិយ៉ាងច្រើន ហើយចិត្តដែលប្រកបដោយគុណ នោះវិសេសជាងប្រាក់នឹងមាសផង»។

## **ការអនុវត្ត**

ចូរទូលសូមប្រាជ្ញាពីព្រះជាម្ចាស់ ពីព្រោះទ្រង់គឺជាប្រភពនៃប្រាជ្ញា (យ៉ាកុប ១:៥)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៊ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# សាស្តា

## អ្នកនិពន្ធ
ស្តេច សាឡូម៉ូន គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ សាស្តា ១:១ បាន ចែងថា «ពាក្យទាំងនេះជាពាក្យរបស់គ្រូប្រដៅដែលជាបុត្ររបស់ដាវីឌ ស្តេចនៅក្រុងយេរូសាឡិម» (អានបន្ថែម សាស្តា ១:១៦, ២:៤-១១)។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៩០០ មុន គ.ស។

## ការសង្ខេប
ជីវិតដែលគ្មានព្រះជាម្ចាស់ គឺជាជីវិតដែលគ្មានប្រយោជន៍។

## គម្រោងកណ្ឌគម្ពីរ
I. បញ្ហានៃការឥតប្រយោជន៍ទទេៗ ជំពូក ១:១-១១

II. ភស្តុតាងនៃការឥតប្រយោជន៍ទទេៗ ជំពូក ១:១២-៦:១-១២

III. ការបង្ហាញពីរបៀបរស់នៅជាមួយការឥតប្រយោជន៍ទទេៗ ជំពូក ៧-១២

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
សាស្តា ១២:១៣-១៤ «សេចក្តីនេះចប់តែប៉ុណ្ណេះ ទាំងអស់បាន សំដែងទុកហើយ ដូច្នេះ ចូរកោតខ្លាចដល់ព្រះ ហើយកាន់តាមបញ្ញត្ត ទ្រង់ចុះ ដ្បិតប៉ុណ្ណេះឯងជាកិច្ចទាំងមូលដែលមនុស្សត្រូវធ្វើ ពីព្រោះ ព្រះទ្រង់នឹងនាំគ្រប់ការទាំងអស់មក ដើម្បីជំនុំជំរះ ព្រមទាំងអ្វីៗដែល លាក់កំបាំងផង ទោះល្អឬអាក្រក់ក្តី»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ការអនុវត្ត

ចូរកោតខ្លាចដល់ព្រះជាម្ចាស់ក្នុងគ្រប់ទាំងផ្លូវនៃការរស់នៅរបស់លោកអ្នក ពីព្រោះការនោះ គឺជាការតែមួយគត់ដែលមានប្រយោជន៍ (សាស្តា ១២:១៣-១៤)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# បទចំរៀងសាឡូម៉ូន

## អ្នកនិពន្ធ

ស្តេច សាឡូម៉ូន គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ បទចំរៀងសាឡូម៉ូន ១:១ “នេះជាចំរៀងដែលប្រសើរបំផុតជាងអស់ទាំងចំរៀងជាទំនុករបស់ស្តេចសាឡូម៉ូន”។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៩៧០-៩៣០ មុន គ.ស នៅពេលដែលស្តេចសាឡូម៉ូន សោយរាជ្យ។

## ការសង្ខេប

ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យបុរស និងស្ត្រីរៀបការសិនមុននឹងរស់នៅជាមួយគ្នា។

## គម្រោងកណ្ឌគម្ពីរ

I. ការចែចង់គ្នា ជំពូក ១-៣

II. ការក្រេបទឹកឃ្មុំ ជំពូក ៤-៥

III. ការរស់នៅដោយក្តីស្រឡាញ់ ជំពូក ៥-៨



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

បទចំរៀងសាឡូម៉ូន ៨:៧ “ទឹកជាច្រើនយ៉ាងណាក៏មិនអាចនឹងពន្លត់សេចក្តីស្រឡាញ់បានឡើយ ទឹកជំនន់នឹងពន្លិចក៏មិនបានដែរ ទោះបើអ្នកណានឹងចំណាយទ្រព្យសម្បត្តិនៅផ្ទះខ្លួនអស់រលីងឲ្យបានសេចក្តីស្រឡាញ់ គង់តែអ្នកនោះនឹងត្រូវបានសេចក្តីមើលងាយទទេៗវិញ»។

## ការអនុវត្ត

ចំពោះទំនាក់ទំនងរវាងបុរសនិងស្ត្រី ចូរកុំទុំមុនស្រគាល (បទចំរៀងសាឡូម៉ូន ២:៧)។

## រូបភាព

**រុក្ខជាតិ - បទចំរៀងសាឡូម៉ូន ៤:១៤**




១) ទេព្វិរូ ២) រមៀត ៣) ដើមកន្ទាយ ៤) សម្បុរល្វែង ៥) ជ័រល្វីងទេស ៦) ក្រឹស្នា



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# អេសាយ

## អ្នកនិពន្ធ

ហោរា អេសាយ ដែលជាកូនរបស់អ័ម៉ូស គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ អេសាយ ១:១ បានចែងថា “នេះជាការជាក់ស្ដែងដែលអេសាយ...បានឃើញ...»។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៧៤០-៧០០ មុន គ.ស កណ្ឌគម្ពីរនេះចាប់ផ្ដើម “នៅឆ្នាំដែលស្ដេចអ៊ូសៀសទ្រង់បានសុគត» (៦:១)។

## ការសង្ខេប

ហោរា អេសាយ រៀបរាប់អំពីគម្រោងនៃការវិនិច្ឆ័យ និងការសង្គ្រោះរបស់ព្រះជាម្ចាស់យ៉ាងល្អិតល្អន់។

## គម្រោងកណ្ឌគម្ពីរ

I. សេចក្ដីក្រោធរបស់ព្រះជាម្ចាស់ ជំពូក ១-៣៩

II. ការប្រោសលោះរបស់ព្រះជាម្ចាស់ ជំពូក ៤០-៦៦

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

អេសាយ ៦:៣ “មួយបន្លឺទៅកាន់១ថា បរិសុទ្ធ បរិសុទ្ធ គឺព្រះយេហូវ៉ា នៃពួកពលបរិវារទ្រង់បរិសុទ្ធ ផែនដីទាំងមូលមានពេញដោយសិរីល្អនៃទ្រង់»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

អេសាយ ៧:១៤ «ដូច្នេះព្រះអម្ចាស់ទ្រង់នឹងប្រទានទីសំគាល់១មក អ្នករាល់គ្នា ដោយព្រះអង្គទ្រង់ មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូត បានបុត្រា១ហើយនឹងឲ្យព្រះនាមថា អេម៉ាញ៉ូអែល»។

អេសាយ ៩:៦ «ដ្បិតមានបុត្រ១កើតដល់យើង ព្រះទ្រង់ប្រទានបុត្រា១ មកយើងហើយ ឯការគ្រប់គ្រងនឹងនៅលើស្មារបស់បុត្រនោះ ហើយ គេនឹងហៅព្រះនាមទ្រង់ថា ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មាន ព្រះចេស្តា ព្រះវរបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព»។

អេសាយ ៥៣:៦ «យើងទាំងអស់គ្នាបានទាសចេញដូចជាចៀម គឺ យើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន ហើយព្រះយេហូវ៉ាបាន ទំលាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់»។

## ការអនុវត្ត

ដោយសារតែព្រះយេស៊ូវបានបំពេញទំនាយរបស់ហោរា អេសាយ (និងហោរាផ្សេងៗទៀត) ដែលយើងឃើញនៅក្នុងព្រះគម្ពីរសញ្ញាថ្មី នោះបញ្ជាក់ថា ទ្រង់គឺជាព្រះសង្គ្រោះ ដូច្នេះលោកអ្នកត្រូវជឿលើទ្រង់ ប្រសិនបើលោកអ្នកចង់ទទួលបានសេចក្ដីសង្គ្រោះ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# យេរេមា

## អ្នកនិពន្ធ

ហោរា យេរេមា គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ យេរេមា ១:១ បានចែងថា «នេះជាពាក្យរបស់យេរេមា...» ប៉ុន្តែលោក បារូក គឺជាអ្នកកត់ត្រា (យេរេមា ៣៦:៤)។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៦២៦-៥៨៦ មុន គ.ស។

## ការសង្ខេប

ព្រះជាម្ចាស់នឹងជំនុំជម្រះសាសន៍យូដា ពីព្រោះពួកគេបានប្រព្រឹត្តអំពើបាប។

## គម្រោងកណ្ឌគម្ពីរ

I. ការត្រាស់ហៅហោរា យេរេមា ជំពូក ១
II. ទំនាយសម្រាប់សាសន៍យូដា ជំពូក ២-៤៥
III. ទំនាយសម្រាប់សាសន៍ដទៃ ជំពូក ៤៦-៥១
IV. ការធ្លាក់ចុះនៃក្រុងយេរូសាឡិម ជំពូក ៥២

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

យេរេមា ៧:២៣ «គឺអញបានបង្គាប់សេចក្ដីនេះដល់គេវិញថា ចូរស្តាប់តាមពាក្យអញ នោះអញនឹងធ្វើជាព្រះដល់ឯងរាល់គ្នា ហើយឯងរាល់គ្នានឹងបានជារាស្ត្ររបស់អញ ត្រូវឲ្យឯងរាល់គ្នាដើរតាមផ្លូវដែលអញបង្គាប់ឯងគ្រប់ចំពូក ដើម្បីឲ្យឯងបានសេចក្ដីសុខស្រួល»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

យេរេមា ២៤:៧ «អញនឹងឲ្យគេមានចិត្តដែលស្គាល់អញថា ជាព្រះយេហូវ៉ា នោះគេនឹងបានជារាស្ត្ររបស់អញ ហើយអញនឹងធ្វើជាព្រះរបស់គេ ពីព្រោះគេនឹងវិលមកឯអញដោយអស់ពីចិត្ត»។

## ការអនុវត្ត

កុំទៅតាមព្រះដទៃ ដើម្បីនឹងគោរព ហើយថ្វាយបង្គំដល់វាឡើយ ប៉ុន្តែចូរទៅតាមព្រះជាម្ចាស់ ដើម្បីនឹងគោរព ហើយនិងថ្វាយបង្គំទ្រង់វិញ (យេរេមា ២៥:៦)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# បរិទេវ

## អ្នកនិពន្ធ
ប្រពៃណីអ៊ីស្រាអែលសន្មតថាហោរា យេរេមា គឺជាអ្នកនិពន្ធកណ្ឌគម្ពីរបរិទេវ ប៉ុន្តែព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ
ក្រោយឆ្នាំ ៥៨៦ មុន គ.ស ពេលក្រុងយេរូសាឡិមដួលរលំ។

## ការសង្ខេប
កំណាព្យដ៏អស់សង្ឃឹមមួយ ស្តីពីការដួលរលំនៃក្រុងយេរូសាឡិម ដោយសារតែអំពើបាបរបស់ពួកគេ ប៉ុន្តែព្រះជាម្ចាស់នឹងស្តារពួកគេឡើងវិញប្រសិនបើពួកគេប្រែចិត្ត។

## គម្រោងកណ្ឌគម្ពីរ
I. សំណង់បែកបាក់នៃក្រុងយេរូសាឡិម ជំពូក ១

II. សេចក្តីក្រោធរបស់ព្រះជាម្ចាស់ ជំពូក ២

III. ការទូលសូមសេចក្តីមេត្តាករុណា ជំពូក ៣

IV. ការរំឭកពីការឡោមព័ទ្ធច្បាំង ជំពូក ៤

V. ការស្នើសុំឲ្យតាំងឡើងវិញ ជំពូក ៥

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
បរិទេវ ៣:២២-២៣ «គឺនឹកពីសេចក្តីនេះថា កុំតែមានសេចក្តីសប្បុរសរបស់ព្រះយេហូវ៉ា នោះយើងបានសូន្យបាត់អស់រលីងទៅហើយ ឯសេចក្តីមេត្តាករុណារបស់ទ្រង់ នោះមិនចេះផុតឡើយ សេចក្តីទាំង



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

នោះ ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច សេចក្ដីស្មោះត្រង់របស់ទ្រង់
ធំណាស់»។

## ការអនុវត្ត

ទោះបីជាយើងជួបទុក្ខលំបាកធំប៉ុណ្ណាក៏ដោយ ក៏ព្រះជាម្ចាស់នៅតែ
មានសេចក្ដីមេត្តាករុណា ហើយស្មោះត្រង់ដដែល ដូច្នេះចូរអំពាវនាវរក
ទ្រង់ចុះ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# អេសេគាល

## អ្នកនិពន្ធ
ហោរា អេសេគាល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ អេសេគាល ១:១-៣ បានចែងថា «...នោះព្រះបន្ទូលនៃព្រះយេហូវ៉ាក៏មកដល់អេសេគាល...»។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ៥៩៣-៥៧១ មុន គ.ស។

## ការសង្ខេប
ទោះបីជាសាសន៍អ៊ីស្រាអែលកំពុងជាប់ជាឈ្លើយក៏ដោយ ក៏ព្រះជាម្ចាស់ស្តារពួកគេឡើងវិញដែរ។

## គម្រោងកណ្ឌគម្ពីរ
I. សេចក្តីក្រោធរបស់ព្រះជាម្ចាស់ ជំពូក ១-៣២
II. ការស្តារឡើងវិញ ជំពូក ៣៣-៤៨

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
អេសេគាល ១១:១៩-២០ «រួចអញនឹងឲ្យគេមានចិត្តតែ១ ហើយនឹងដាក់វិញ្ញាណថ្មី នៅក្នុងឯងរាល់គ្នា អញនឹងដកចិត្តដែលរឹងដូចថ្មពីរូបសាច់គេចេញ ហើយនឹងឲ្យមានចិត្តជាសាច់វិញ ដើម្បីឲ្យគេបានប្រព្រឹត្តតាមក្រឹត្យក្រមរបស់អញ ហើយរក្សាបញ្ញត្តច្បាប់របស់អញ ព្រមទាំងប្រព្រឹត្តតាមផង នោះគេនឹងបានជារាស្ត្ររបស់អញ ហើយអញនឹងធ្វើជាព្រះដល់គេ»។


រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៊ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

អេសេគាល ៣៦:២៦ “អញនឹងឲ្យឯងមានចិត្តថ្មី ហើយនឹងដាក់វិញ្ញាណថ្មីនៅក្នុងឯងដែរ អញនឹងដកចិត្តដែលរឹងដូចថ្ម ពីរូបសាច់ឯងចេញ រួចនឹងឲ្យមានចិត្តជាសាច់វិញ”។

## ការអនុវត្ត

ចូរប្រែចិត្ត ហើយរស់នៅដោយស្តាប់បង្គាប់តាមព្រះជាម្ចាស់ ពីព្រោះទ្រង់នឹងជំនុំជម្រះគ្រប់ទាំងការដែលយើងប្រព្រឹត្ត។

## រូបភាព



តួមានជីវិតបួនរូប និងកង់ - អេសេគាល ១:៥, ១៥-១៦



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូ | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# ដានីយ៉ែល

## អ្នកនិពន្ធ
ហោរា ដានីយ៉ែល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរដានីយ៉ែលផ្ទាល់ បានបញ្ជាក់ថា «ខ្ញុំ ដានីយ៉ែល...» នៅជំពូក ៧:១៥។ ហើយនៅក្នុង កណ្ឌគម្ពីរ ម៉ាថាយ ២៤:១៥ ព្រះយេស៊ូវក៏បានបញ្ជាក់ថែមទៀតថា ហោរា ដានីយ៉ែល ជាអ្នកនិពន្ធ។ ស្តេច នេប៊ូក្នេសា គឺជាអ្នកនិពន្ធ ជំពូក៤។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ៦០៥-៥៣៨ មុន គ.ស នៅពេលដែលសាសន៍យូដា បានក្លាយទៅជាឈ្លើយរបស់សាសន៍បាប៊ីឡូន។

## ការសង្ខេប
កណ្ឌគម្ពីរនេះរៀបរាប់អំពីអធិបតីភាពរបស់ព្រះជាម្ចាស់។

## គម្រោងកណ្ឌគម្ពីរ
I. សេចក្តីផ្តើម៖ ព្រឹត្តិការណ៍ ជំពូក ១

II. វាសនារបស់សាសន៍ដទៃ ជំពូក ២-៧

III. វាសនារបស់សាសន៍អ៊ីស្រាអែល ជំពូក ៨-១២



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ដានីយ៉ែល ៣:១៧ «បើជាយ៉ាងនោះមែន នោះព្រះនៃយើងខ្ញុំ ដែលយើងខ្ញុំគោរពប្រតិបត្តិតាម ទ្រង់អាចនឹងជួយឲ្យយើងខ្ញុំរួចពីគុកភ្លើងដែលឆេះយ៉ាងសន្ធៅបានហើយ បពិត្រព្រះករុណា ព្រះអង្គនោះក៏នឹងជួយឲ្យយើងខ្ញុំរួចពីព្រះហស្តទ្រង់ដែរ»។

ដានីយ៉ែល ៦:២២ «ព្រះនៃទូលបង្គំទ្រង់បានចាត់ទេវតារបស់ទ្រង់ ឲ្យមកបិទមាត់សិង្ហទាំងអស់ វាមិនបានប្រទូស្តដល់ទូលបង្គំទេ ពីព្រោះនៅចំពោះព្រះ នោះមិនឃើញជាទូលបង្គំមានទោសអ្វីឡើយ ហើយបពិត្រព្រះករុណា នៅចំពោះទ្រង់ ទូលបង្គំក៏មិនបានធ្វើខុសអ្វីដែរ»។

ដានីយ៉ែល ៩:១៨ «ឱព្រះនៃទូលបង្គំអើយ សូមផ្អៀងព្រះកាណ៌មកស្តាប់ សូមបើកព្រះនេត្រទ្រង់ទតមើលសេចក្តីខូចបង់របស់យើងខ្ញុំ និងទីក្រុងដែលបានហៅតាមព្រះនាមទ្រង់ ដ្បិតយើងខ្ញុំមិនមែនទូលអង្វរដល់ទ្រង់ ដោយព្រោះយើងខ្ញុំមានសេចក្តីសុចរិតទេ គឺដោយព្រោះតែសេចក្តីមេត្តាករុណាដ៏ធំរបស់ទ្រង់វិញ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរចុះចូលចំពោះរដ្ឋាភិបាល ទោះបីជាពួកគេធ្វើបាបលោកអ្នកក៏ដោយ ពីព្រោះព្រះជាម្ចាស់គ្រប់គ្រងលើសកម្មភាពទាំងអស់ លុះត្រាតែពួកគេបង្ខំឲ្យលោកអ្នកមិនស្ដាប់បង្គាប់ទ្រង់។

## រូបភាព



សត្វទាំងបួន - ដានីយ៉ែល ៧



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូ | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ហូសេ

## អ្នកនិពន្ធ

ហោរា ហូសេ គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ហូសេ ១:១ បានចែងថា «នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ាដែលមកដល់ហូសេ...»។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៧៥០-៧២២ មុន គ.ស នៅពេលដែលប្រទេសអាសស៊ើរមកច្បាំងយកសាសន៍អ៊ីស្រាអែលធ្វើជាឈ្លើយ។

## ការសង្ខេប

ទោះបីជាសាសន៍អ៊ីស្រាអែលមានសេចក្តីស្រឡាញ់ចំពោះព្រះជាម្ចាស់មិនស្មោះត្រង់ក៏ដោយ ក៏ទ្រង់នៅតែស្រឡាញ់ពួកគេយ៉ាងស្មោះត្រង់ដដែល។

## គម្រោងកណ្ឌគម្ពីរ

I. ប្រពន្ធកំផិត តែប្តីស្មោះត្រង់ ជំពូក ១-៣

II. សាសន៍អ៊ីស្រាអែលកំផិត តែព្រះជាម្ចាស់ស្មោះត្រង់ ជំពូក ៤-១៤

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ហូសេ ២:១៩-២០ «នោះអញនឹងដណ្តឹងនាងសំរាប់អញ ទុកជាដរាបតទៅ អើ អញនឹងដណ្តឹងនាងសំរាប់អញ ដោយសេចក្តីសុចរិត សេចក្តីយុត្តិធម៌ សេចក្តីសប្បុរស និងសេចក្តីមេត្តាករុណា ក៏នឹងដណ្តឹងនាងសំរាប់អញ ដោយសេចក្តីស្មោះត្រង់ផង នោះនាងនឹងបានស្គាល់ព្រះយេហូវ៉ា»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

ហូសេ ១២:៦ «គឺព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ «យេហូវ៉ា» នេះជានាមដ៏ជាទីរំឭកពីទ្រង់»។

ហូសេ ១៤:៤, ៩ «អញនឹងកែការរាថយរបស់គេឲ្យជា ហើយអញនឹងស្រឡាញ់គេស្ម័គ្រពីចិត្ត ដ្បិតសេចក្ដីកំហឹងរបស់អញបានបែរចេញពីគេហើយ...តើមានអ្នកណា ដែលមានប្រាជ្ញា ឲ្យយល់សេចក្ដីទាំងនេះបាន ឬមានគំនិតវាងវៃឲ្យបានស្គាល់សេចក្ដីទាំងនេះផង ដ្បិតអស់ទាំងផ្លូវរបស់ព្រះយេហូវ៉ាសុទ្ធតែទៀងត្រង់ ពួកអ្នកសុចរិតនឹងដើរក្នុងផ្លូវទាំងនោះ តែមនុស្សទុច្ចរិតនឹងចំពប់ដួលក្នុងផ្លូវនោះវិញ»។

## ការអនុវត្ត

ចូរស្មោះត្រង់នឹងព្រះជាម្ចាស់ ហើយឆាប់នឹងអត់ទោសដល់អ្នកដទៃផង ដូចហោរា ហូសេ ស្មោះត្រង់ ហើយឆាប់នឹងអត់ទោសដល់ប្រពន្ធរបស់គាត់យ៉ាងដូច្នោះដែរ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# យ៉ូអែល

## អ្នកនិពន្ធ

ហោរា យ៉ូអែល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ យ៉ូអែល ១:១ បាន ថែងថា «នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ាដែលបានមកដល់យ៉ូអែល ជាកូនពេធូអែល»។

## ឆ្នាំនិពន្ធ

ប្រហែលក្នុងឆ្នាំ ៨៣០ មុន គ.ស។

## ការសង្ខេប

ការដែលកណ្ដូបស៊ីដំណាំបង្ហាញពីការដែលព្រះជាម្ចាស់វិនិច្ឆ័យទោស ចំពោះអស់អ្នកដែលប្រព្រឹត្តអំពើបាប។

## គម្រោងកណ្ឌគម្ពីរ

I. ថ្ងៃនៃព្រះយេហូវ៉ាក្នុងអតីតកាល ជំពូក ១
II. ថ្ងៃនៃព្រះយេហូវ៉ានាអនាគតកាល ជំពូក ២-៣

## សំណេរីខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

យ៉ូអែល ២:២៨-២៩ «ក្រោយគ្រានោះ អញនឹងចាក់វិញ្ញាណរបស់ អញទៅលើគ្រប់ទាំងមនុស្ស នោះកូនប្រុសស្រីរបស់ឯងនឹងទាយ ពួកចាស់ៗរបស់ឯងនឹងយល់សប្តិឃើញ ហើយពួកកំឡោះៗរបស់ឯង នឹងឃើញការជាក់ស្តែង នៅគ្រានោះ អញនឹងចាក់វិញ្ញាណរបស់អញ ទៅលើទាំងពួកទាសាទាសីដែរ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ការអនុវត្ត

ចូរប្រែចិត្តមុនថ្ងៃនៃព្រះយេហូវ៉ាមកដល់ ពីព្រោះទ្រង់នឹងវិនិច្ឆ័យទោស
នៅពេលដែលទ្រង់យាងមក។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# អេម៉ុស

## អ្នកនិពន្ធ
ហោរា អេម៉ុស គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ អេម៉ុស ១:១ បានចែង ថា “នេះជាពាក្យរបស់អេម៉ុស ជាម្នាក់ក្នុងពួកគង្វាលនៅត្កូអា...”។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៧៦០ មុន គ.ស។

## ការសង្ខេប
សាសនាដែលបរិសុទ្ធ ហើយឥតសៅហ្មង គឺជាសាសនាដែលប្រព្រឹត្តិ សេចក្ដីយុត្តិធម៌ចំពោះមនុស្សផ្សេងៗ មិនមែនគ្រាន់តែជឿតែមាត់ដោយ គ្មានការប្រព្រឹត្តនោះទេ។

## គម្រោងកណ្ឌគម្ពីរ
I. ទុក្ខលំបាកប្រាំបីយ៉ាង ជំពូក ១-២
II. សម្ដីបីម៉ាត់ ជំពូក ៣-៦
III. ការជាក់ស្ដែងប្រាំយ៉ាង ជំពូក ៧-៩



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

អេម៉ុស ៥:១៤, ២៤ “ចូរស្វែងរកសេចក្ដីល្អ កុំរកសេចក្ដីអាក្រក់ឡើយ ដើម្បីឲ្យឯងរាល់គ្នាបានរស់នៅ យ៉ាងនោះព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ ទ្រង់នឹងគង់នៅជាមួយនឹងឯងជាពិតដូចជាឯងធ្លាប់ថាហើយ...តែត្រូវឲ្យមានសេចក្ដីយុត្តិធម៌ហូរមកដូចជាទឹក ហើយសេចក្ដីសុចរិតដូចជាទន្លេធំវិញ”។

## ការអនុវត្ត

“ចូរស្អប់អំពើអាក្រក់ ហើយស្រឡាញ់អំពើល្អវិញ ចូរតាំងឲ្យមានសេចក្ដីយុត្តិធម៌...” (អេម៉ុស ៥:១៥)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# អូបាឌា

## អ្នកនិពន្ធ

ហោរា អូបាឌា គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ អូបាឌា ១:១ បានចែងថា “នេះជាការជាក់ស្តែងរបស់អូបាឌា...”។

## ឆ្នាំនិពន្ធ

ប្រហែលនៅឆ្នាំ ៨៥០ មុន គ.ស ក្នុងរាជ្យស្តេច យ៉ូរ៉ាម នៅពេលដែលប្រទេសអេដំមជាខ្មាំងសត្រូវរបស់សាសន៍អ៊ីស្រាអែល។

## ការសង្ខេប

ព្រះជាម្ចាស់នឹងវិនិច្ឆ័យទោសសាសន៍អេដំម ពីព្រោះពួកគេបានចូលរួមជាមួយសាសន៍ដទៃក្នុងការបំផ្លិចបំផ្លាញសាសន៍អ៊ីស្រាអែល ប៉ុន្តែទ្រង់នឹងស្តារសាសន៍អ៊ីស្រាអែលឡើងវិញ។

## គម្រោងកណ្ឌគម្ពីរ

I. ការបំផ្លិចបំផ្លាញប្រទេសអេដំម ខ១-៩

II. ហេតុផលនៃការបំផ្លិចបំផ្លាញប្រទេសអេដំម ខ១០-១៦

III. ជ័យជម្នះរបស់សាសន៍អ៊ីស្រាអែល ខ១៧-២០



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

១២០ «ឯពួកពលទ័ពនៃកូនចៅអ៊ីស្រាអែលដែលជាប់ជាឈ្លើយ គេ
នឹងបានស្រុករបស់ពួកសាសន៍កាណាន រហូតដល់ក្រុងសារិបតា
ហើយពួកក្រុងយេរូសាឡិមដែលនៅជាឈ្លើយ ត្រង់សេផារ៉ាឌ គេនឹង
បានអស់ទាំងទីក្រុងនៅស្រុកត្បូង នោះនឹងមានពួកអ្នកដែលបាន
សង្គ្រោះឡើងមកឯភ្នំស៊ីយ៉ូន ដើម្បីនឹងជំនុំជំរះស្រុកភ្នំរបស់អេសាវ
ហើយរាជ្យនោះនឹងបានជារបស់ផងព្រះយេហូវ៉ា»។

## ការអនុវត្ត

ចូរចុះចូលចំពោះព្រះជាម្ចាស់ ដ្បិតនគររបស់ទ្រង់នឹងមានជ័យជម្នះ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# យ៉ូណាស

## អ្នកនិពន្ធ
ហោរា យ៉ូណាស គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ យ៉ូណាស ១:១ បានចែងថា “រីឯព្រះបន្ទូលនៃព្រះយេហូវ៉ា បានមកដល់យ៉ូណាស...”។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៧៦០ មុន គ.ស នៅពេលដែលស្តេច យេរ៉ូបោម សោយរាជ្យ (សូមអានបន្ថែម ២ពង្សាវតារក្សត្រ ១៤:២៥)។

## ការសង្ខេប
ហោរា យ៉ូណាស គឺជាហោរាដែលមានការស្ទាក់ស្ទើរក្នុងការបម្រើព្រះជាម្ចាស់ ដោយមិនចង់ប្រាប់ពីសេចក្តីសង្គ្រោះដល់ក្រុងនីនីវេ។

## គម្រោងកណ្ឌគម្ពីរ
I. សេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះហោរា យ៉ូណាស ជំពូក ១-២

II. សេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះក្រុងនីនីវេ ជំពូក ៣-៤



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

យ៉ូណាស ៤:២ «រួចលោកអធិស្ឋានដល់ព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ាអើយ តើមិនមែនជាសេចក្ដីនេះឯងដែលទូលបង្គំបានថា ក្នុងកាលដែលទូលបង្គំនៅឯស្រុករបស់ទូលបង្គំនៅឡើយទេឬអី គឺដោយហេតុនោះ បានជាទូលបង្គំខំរត់ទៅឯក្រុងតើស៊ីសវិញ ពីព្រោះទូលបង្គំបានដឹងថា ទ្រង់ជាព្រះដ៏ប្រកបដោយករុណាគុណ ក៏មានព្រះហឫទ័យអាណិតអាសូរ ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្ដីសប្បុរសជាបរិបូរ ក៏តែងតែប្រែគំនិតចេញពីការអាក្រក់ផង»។

## ការអនុវត្ត

ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យមនុស្សគ្រប់រូបប្រែចិត្ត ដូច្នេះចូរផ្សាយដំណឹងល្អ ទោះបីជាពួកគេជាខ្មាំងសត្រូវរបស់យើងក៏ដោយ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# មីកា

## អ្នកនិពន្ធ
ហោរា មីកា គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ មីកា ១:១ បានថែងថា «នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ាដែលមកដល់មីកា»។

## ឆ្នាំនិពន្ធ
ប្រហែលមុនឆ្នាំ ៦៨៦ មុន គ.ស។

## ការសង្ខេប
ការរៀបរាប់របស់ហោរា មីកា ស្ដីពីទំនាយនៃការដាក់ទោស និង ការផ្ដល់ក្ដីសង្ឃឹមដល់ប្រទេសអ៊ីស្រាអែល។

## គម្រោងកណ្ឌគម្ពីរ
I. ទំនាយនៃការដាក់ទោស ជំពូក ១-៣

II. ទំនាយនៃការស្ដារឡើងវិញ ជំពូក ៤-៥

III. ការអង្វរករឲ្យប្រែចិត្ត ជំពូក ៦-៧

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
មីកា ៧:៧ «ឯចំណែកខ្លួនខ្ញុំៗនឹងទុកចិត្តដល់ព្រះយេហូវ៉ា ខ្ញុំនឹងរង់ចាំព្រះដ៏ជួយសង្គ្រោះខ្ញុំ ព្រះនៃខ្ញុំទ្រង់នឹងស្ដាប់ខ្ញុំ»។

## ការអនុវត្ត
ចូរប្រព្រឹត្តចំពោះអ្នកដទៃដោយយុត្តិធម៌ ពីព្រោះព្រះជាម្ចាស់ស្អប់សេចក្ដីអយុត្តិធម៌។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# ណាហ៊ុម

## អ្នកនិពន្ធ

ហោរា ណាហ៊ុម គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ណាហ៊ុម ១:១ បានចែងថា «នេះជាសេចក្តីទំនាយយ៉ាងធ្ងន់ពីដំណើរក្រុងនីនីវេ គឺជាសៀវភៅសំដែងចេញជាការជាក់ស្តែងរបស់ណាហ៊ុមជាអ្នកប្រទេសអែលកូស»។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៦៦៣-៦១២ មុន គ.ស។

## ការសង្ខេប

ព្រះជាម្ចាស់នឹងវិនិច្ឆ័យសាសន៍នីនីវេ ពីព្រោះពួកគេជាមនុស្សអាក្រក់ ហើយពោរពេញទៅដោយអំនួត។

## គម្រោងកណ្ឌគម្ពីរ

I. តេជានុភាពដ៏បរិសុទ្ធនៃព្រះជាម្ចាស់ ជំពូក ១

II. ការវិនិច្ឆ័យទោសសាសន៍នីនីវេ ជំពូក ២-៣

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ណាហ៊ុម ១:៣ «ព្រះយេហូវ៉ាទ្រង់យឺតនឹងខ្ញាល់ ហើយមានព្រះចេស្តាយ៉ាងធំ ទ្រង់មិនលះលែងទោសរបស់មនុស្សឡើយ ឯផ្លូវរបស់ព្រះយេហូវ៉ា នោះនៅក្នុងខ្យល់កួច ហើយក្នុងព្យុះសង្ឃរា ពពកទាំងឡាយជាធូលីហុយពីព្រះបាទទ្រង់»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.0
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# ការអនុវត្ត

ចូរចុះចូលចំពោះព្រះជាម្ចាស់ ពីព្រោះទ្រង់គឺជាព្រះលើអស់ទាំងព្រះ
ហើយក៏គ្រប់គ្រងលើអ្វីៗទាំងអស់។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ហាបាគុក

## អ្នកនិពន្ធ

ហោរា ហាបាគុក គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ហាបាគុក ១:១ បានចែងថា «នេះជាសេចក្ដីទំនាយយ៉ាងធ្ងន់ ដែលហោរាហាបាគុក បានឃើញ»។

## ឆ្នាំនិពន្ធ

ប្រហែលក្នុងឆ្នាំ ៦១០ មុន គ.ស។

## ការសង្ខេប

ការសន្ទនារវាងហោរា ហាបាគុក ជាមួយនឹងព្រះជាម្ចាស់។

## គម្រោងកណ្ឌគម្ពីរ

I. សេចក្ដីសន្ទនាទី១៖ ចុះពួកមនុស្សអាក្រក់? ជំពូក ១:១-១១
II. សេចក្ដីសន្ទនាទី២៖ ចុះពួកខ្មាំងសត្រូវ? ជំពូក ១:១២-២:២០
III. សេចក្ដីបញ្ចប់របស់ហោរា ហាបាគុក ជំពូក ៣

## សំណេរគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ហាបាគុក ២:៤ «មើល ចិត្តគេបានប៉ោងឡើង មិនទៀងត្រង់នៅក្នុងខ្លួនគេទេ តែមនុស្សសុចរិតនឹងរស់នៅ ដោយសារសេចក្ដីជំនឿរបស់ខ្លួន»។

ហាបាគុក ៣:១៨-១៩ «គង់តែខ្ញុំនឹងរីករាយ ដោយសារព្រះយេហូវ៉ា ខ្ញុំនឹងអរសប្បាយក្នុងព្រះដ៏ជួយសង្គ្រោះខ្ញុំដែរ ព្រះយេហូវ៉ា គឺជា



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

ព្រះអម្ចាស់ទ្រង់ជាកំឡាំងខ្ញុំ ទ្រង់នឹងធ្វើឲ្យជើងនៃខ្ញុំបានលឿន ដូចជាជើងឈ្លូស ហើយឲ្យខ្ញុំដើរនៅលើទីខ្ពស់របស់ខ្ញុំ នេះលើកសំរាប់មេភ្លេងឲ្យលេងដោយប្រដាប់មានខ្សែរបស់ខ្ញុំ»។

## ការអនុវត្ត

ចូរចំណាយពេលសន្ទនាជាមួយនឹងព្រះជាម្ចាស់ដូច
ហោរា ហាបាគុក។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# សេផានា

## អ្នកនិពន្ធ

ហោរា សេផានា គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ សេផានា ១:១ បានចែងថា «នេះជាព្រះបន្ទូលនៃព្រះយេហូវ៉ាដែលបានមកដល់សេផានា...»។

## ឆ្នាំនិពន្ធ

ប្រហែលក្នុងឆ្នាំ ៦៣០ មុន គ.ស នៅពេលដែលស្តេច យ៉ូសៀសសោយរាជ្យ។

## ការសង្ខេប

ថ្ងៃនៃព្រះយេហូវ៉ានឹងមកដល់ដោយមានទាំងការវិនិច្ឆ័យទោស និងការប្រទានពរ។

## គម្រោងកណ្ឌគម្ពីរ

I. ទំនាយនៃការវិនិច្ឆ័យទោស ជំពូក ១-២

II. ទំនាយនៃការប្រទានពរ ជំពូក ៣

## សំណេរីខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

សេផានា ១:១៤ «ថ្ងៃដ៏ធំរបស់ព្រះយេហូវ៉ាជិតមកដល់ គឺបានមកជិតហើយ ក៏ប្រញាប់ណាស់ដែរ គឺឮសូរថ្ងៃនៃព្រះយេហូវ៉ាហើយ វេលានោះពួកមនុស្សខ្លាំងពូកែ នឹងស្រែកឡើងយ៉ាងជូរចត់»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

សេផានា ៣:១៧ «ព្រះយេហូវ៉ា ដ៏ជាព្រះនៃឯង ទ្រង់គង់នៅកណ្តាលឯង ទ្រង់ជាព្រះដ៏មានឥទ្ធិឫទ្ធិ ដើម្បីជួយសង្គ្រោះ ទ្រង់នឹងមានសេចក្តីរីករាយអរសប្បាយចំពោះឯង ទ្រង់នឹងសំរាកក្នុងសេចក្តីស្រឡាញ់របស់ទ្រង់ ក៏នឹងអរសប្បាយនឹងឯង ដោយសំឡេងច្រៀង»។

## ការអនុវត្ត

ចូរប្រែចិត្ត ពីព្រោះថ្ងៃនៃព្រះយេហូវ៉ាជិតមកដល់ហើយ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# ហាកាយ

## អ្នកនិពន្ធ

ហោរា ហាកាយ គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ហាកាយ ១:១ បាន ចែងថា “ព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់...ហាកាយ”។

## ឆ្នាំនិពន្ធ

នៅក្នុងឆ្នាំ ៥២០ មុន គ.ស “នៅថ្ងៃទី១ ខែភទ្របទក្នុងឆ្នាំទី២នៃរាជ្យស្ដេចដារីយុស” (១:១, អានបន្ថែមកណ្ឌគម្ពីរ អែសរ៉ា ៥:១)។

## ការសង្ខេប

ពួកកូនចៅអ៊ីស្រាអែលដែលបានរួចចេញពីសណ្ឋានជាឈ្លើយត្រឡប់មកវិញមានតួនាទីក្នុងការកសាងព្រះវិហារនៃព្រះជាម្ចាស់។

## គម្រោងកណ្ឌគម្ពីរ

I. បទទំនាយទី១៖ ការទូន្មានឲ្យកសាងព្រះវិហារឡើងវិញ ជំពូក ១

II. បទទំនាយទី២៖ ការលើកទឹកចិត្តឲ្យកសាងព្រះវិហារឡើងវិញ ជំពូក ២:១-៩

III. បទទំនាយទី៣៖ ការប្រទានពរក្នុងការកសាងព្រះវិហារឡើងវិញ ជំពូក ២:១០-១៩

IV. បទទំនាយទី៤៖ ការសង្គ្រោះក្នុងការកសាងព្រះវិហារឡើងវិញ ជំពូក ២:២០-២៣



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ហាកាយ ២:៤ «ទោះបើយ៉ាងនោះ គង់តែព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ឱសូរ៉ូបាបិលអើយ ចូរមានកំឡាំងឥឡូវចុះ ឱយេសួរ ជាកូនយ៉ូសាដាកដ៏ជាសង្ឃធំអើយ ចូរមានកំឡាំងដែរ ឯងរាល់គ្នាជាជនជាតិនៃស្រុកនេះអើយ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា ចូរឯងរាល់គ្នាមានកំឡាំង ហើយធ្វើការទៅ ដ្បិតអញនៅជាមួយនឹងឯងហើយ នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ»។

## ការអនុវត្ត

ចូរដាក់ព័ន្ធកិច្ចរបស់ព្រះជាម្ចាស់ឲ្យខ្ពស់ជាងគេបំផុត នៅក្នុងជីវិតរស់នៅរបស់លោកអ្នក។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# សាការី

## អ្នកនិពន្ធ

ហោរា សាការី គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ សាការី ១:១ បានចែង ថា «ព្រះបន្ទូលនៃព្រះយេហូវ៉ាបានមកដល់ហោរា សាការី»។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៥២០-៤៧០ មុន គ.ស។

## ការសង្ខេប

កណ្ឌគម្ពីរសាការីបានរៀបរាប់អំពីព្រះសង្គ្រោះដែលនឹងត្រូវយាងមក។

## គម្រោងកណ្ឌគម្ពីរ

I. ការជាក់ស្តែងផ្សេងៗ ជំពូក ១-៦

II. សំណួរផ្សេងៗ ជំពូក ៧-៨

III. បន្ទុកផ្សេងៗ ជំពូក ៩-១៤

## សំណេរីខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

សាការី ១:៣ «ហេតុនោះ ចូរឯងប្រាប់គេថា ព្រះយេហូវ៉ា ជាព្រះនៃ ពួកពលបរិវារ ទ្រង់មានបន្ទូលដូច្នេះ ចូរវិលមកឯអញវិញ នេះជា ព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ នោះអញនឹងវិលមកឯ ឯងរាល់គ្នាដែរ នេះក៏ជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

យោងតាមព្រះគម្ពីរសញ្ញាថ្មី ព្រះសង្គ្រោះដែលមានរៀបរាប់នៅក្នុង
កណ្ឌគម្ពីរនេះ គឺមានព្រះនាមថា ព្រះយេស៊ូវគ្រីស្ទ ដូច្នេះចូរជឿលើទ្រង់
ប្រសិនបើលោកអ្នកចង់ទទួលបានសេចក្តីសង្គ្រោះ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.0
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# ម៉ាឡាគី

## អ្នកនិពន្ធ

ហោរា ម៉ាឡាគី គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ម៉ាឡាគី ១:១ បាន ចែងថា «នេះជាព្រះបន្ទូលយ៉ាងធ្ងន់នៃព្រះយេហូវ៉ាដល់អ៊ីស្រាអែល ដោយសារម៉ាឡាគី»។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៤៧៥-៤២០ មុន គ.ស។

## ការសង្ខេប

ហោរា ម៉ាឡាគី បានព្រមានសាសន៍អ៊ីស្រាអែលឲ្យប្រែចិត្ត ពីព្រោះ ពួកគេមិនបានយកចិត្តទុកដាក់លើព្រះជាម្ចាស់។

## គម្រោងកណ្ឌគម្ពីរ

I. អំពើបាបបច្ចុប្បន្ន ជំពូក ១-២

II. ទំនាយពីថ្ងៃអនាគត ជំពូក ៣-៤

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ម៉ាឡាគី ៤:៥-៦ «មើល មុនដែលថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចរបស់ ព្រះយេហូវ៉ាបានមកដល់ នោះអញនឹងចាត់អេលីយ៉ា ឲ្យមកឯឯងរាល់ គ្នា លោកនឹងបង្វែរចិត្តពួកឪពុកមកឯកូន នឹងចិត្តកូនមកឯឪពុកវិញ ក្រែងអញមកវាយផែនដីដោយសេចក្ដីបណ្ដាសា»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ការអនុវត្ត

ចូរថ្វាយបង្គំព្រះជាម្ចាស់តាមរបៀបដែលទ្រង់បានបង្គាប់លោកអ្នកចុះ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# សញ្ញាថ្មី

# ម៉ាថាយ

## អ្នកនិពន្ធ
ប្រពៃណីក្រុមជំនុំដំបូងបានសន្មតថា សាវ័ក ម៉ាថាយ គឺជាអ្នកនិពន្ធ (ម៉ាថាយ ៩:៩, ម៉ាកុស ២:១៤)។

## ឆ្នាំនិពន្ធ
ប្រហែលមុនឆ្នាំ ៧០ នៃគ.ស នៅពេលដែលពួករ៉ូមបានមកបំផ្លាញទីក្រុងយេរូសាឡិម។

## ការសង្ខេប
ព្រះយេស៊ូវគឺជាស្តេច ពីព្រោះទ្រង់បានបំពេញគ្រប់ទាំងទំនាយនៅក្នុងព្រះគម្ពីរសញ្ញាចាស់។

## គម្រោងកណ្ឌគម្ពីរ
I. ការប្រកាសថាព្រះយេស៊ូវ គឺជាស្តេច ជំពូក ១-១០
II. ការបដិសេធថាព្រះយេស៊ូវ គឺជាស្តេច ជំពូក ១១-២៨

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
ម៉ាថាយ ២៨:១៩-២០ “ដូច្នេះ ចូរទៅបង្កើតសិស្សពីគ្រប់ជនជាតិ ហើយធ្វើពិធីជ្រមុជទឹកឲ្យពួកគេនៅក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ហើយបង្រៀនពួកគេឲ្យកាន់តាមសេចក្តីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់ដល់អ្នករាល់គ្នា ហើយមើល៍ ខ្ញុំនៅជាមួយអ្នករាល់គ្នាគ្រប់ពេលវេលារហូតដល់អស់កល្ប” (គគខ)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូ | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរជឿលើព្រះយេស៊ូវព្រោះទ្រង់គឺជាស្តេចដែលអាចថែរក្សាការពារ លោកអ្នកបាន។

## រូបភាព



អ្នកគង្វាលចៀម - ម៉ាថាយ ៩:៣៦



រំពាត់ - ម៉ាថាយ ១០:១៧



ឈើឆ្កាង - ម៉ាថាយ ១០:៣៨



ដើមល្វា - ម៉ាថាយ ២១:១៩



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*




ប្រាក់កាក់ - ម៉ាថាយ ២២:១៩



ផ្នូរជាមួយថ្មប្រមៀល - ម៉ាថាយ ២៧:៦០



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៊ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ម៉ាកុស

## អ្នកនិពន្ធ
ប្រពៃណីក្រុមជំនុំដំបូងបានសន្មតថា លោក យ៉ូហាន-ម៉ាកុស គឺជាអ្នកនិពន្ធ (សូមអានបន្ថែម កិច្ចការ ១២:២៥, ១ពេត្រុស ៥:១៣)។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ៥៥-៧០ នៃគ.ស ជាពេលដែលពួករ៉ូមបានបៀតបៀនគ្រីស្ទបរិស័ទ។

## ការសង្ខេប
ព្រះយេស៊ូវ គឺជាព្រះរាជបុត្រានៃព្រះជាម្ចាស់ ហើយទ្រង់ក៏ជាបាវបម្រើម្នាក់ដែលរងទុក្ខជំនួសប្រជារាស្ត្រទ្រង់ផងដែរ។

## គម្រោងកណ្ឌគម្ពីរ
I. ព្រះជាម្ចាស់បានចាត់ព្រះយេស៊ូវឲ្យមក
   ដើម្បីបម្រើ ជំពូក ១-១០
II. ព្រះជាម្ចាស់បានចាត់ព្រះយេស៊ូវឲ្យមក
   ដើម្បីសង្គ្រោះ ជំពូក ១១-១៦

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
ម៉ាកុស ១០:៤៥ «ដ្បិតកូនមនុស្សក៏បានមក មិនមែនឲ្យគេបំរើដែរ គឺដើម្បីនឹងបំរើគេវិញ ហើយនិងឲ្យជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរបម្រើអ្នកដទៃ ដូចព្រះយេស៊ូវបានបម្រើអ្នកដទៃផងដែរ។

## រូបភាព



សុព័ណ៌ - ម៉ាកុស ១:៧



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# លូកា

## អ្នកនិពន្ធ
ប្រពៃណីក្រុមជំនុំដំបូងបានសន្មតថា លោក លូកា ដែលមានមុខងារ ជាគ្រូពេទ្យ គឺជាអ្នកនិពន្ធ (កូល៉ុស ៤:១៤, ២ធីម៉ូថេ ៤:១១)។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ៥៩-៦៣ នៃគ.ស។

## ការសង្ខេប
ព្រះយេស៊ូវ គឺជាព្រះសង្គ្រោះនៃមនុស្សលោកទាំងអស់ ពីព្រោះទ្រង់ គឺជាកូនមនុស្ស។

## គម្រោងកណ្ឌគម្ពីរ
I. កំណើតនៃកូនមនុស្ស ជំពូក ១-៣

II. ព័ន្ធកិច្ចនៃកូនមនុស្ស ជំពូក ៤-១៩

III. ការជាប់ឆ្កាង និងការរស់ឡើងវិញនៃកូនមនុស្ស ជំពូក ២០-២៤

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
លូកា ១៩:១០ «ដ្បិតកូនមនុស្សបានមក ដើម្បីនឹងរកហើយជួយ សង្គ្រោះដល់មនុស្សបាត់បង់»។

## ការអនុវត្ត
ចូរថ្វាយជីវិតរបស់លោកអ្នកទៅព្រះយេស៊ូវ ពីព្រោះទ្រង់បានយាងមក ដើម្បីសង្គ្រោះលោកអ្នកឲ្យរួចពីបាប មិនថាអំពើបាបនោះធ្ងន់ធ្ងរយ៉ាង ណាក៏ដោយ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# រូបភាព



ស្នូក - លូកា ២:៧



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# យ៉ូហាន

## អ្នកនិពន្ធ
ប្រពៃណីក្រុមជំនុំដំបូងបានសន្មតថា សាវ័ក យ៉ូហាន គឺជាអ្នកនិពន្ធ (យ៉ូហាន ២១:៧, ម៉ាថាយ ៤:២១)។

## ឆ្នាំនិពន្ធ
ប្រហែលនៅចុងឆ្នាំ ៩០ នៃគ.ស។

## ការសង្ខេប
ព្រះយេស៊ូវ គឺជាព្រះសង្គ្រោះតែមួយគត់ សម្រាប់មនុស្សលោកទាំងអស់។

## គម្រោងកណ្ឌគម្ពីរ
I. ព័ន្ធកិច្ចជាសាធារណៈរបស់ព្រះយេស៊ូវ ជំពូក ១-១២

II. ព័ន្ធកិច្ចសម្ងាត់របស់ព្រះយេស៊ូវ ជំពូក ១៣-១៧

III. ការរងទុក្ខលំបាក និងការមានព្រះជន្មរស់ឡើងវិញ របស់ព្រះយេស៊ូវ ជំពូក ១៨-២១

## សំណេរីខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
យ៉ូហាន ២០:៣០-៣១ “ព្រះយេស៊ូវក៏ធ្វើទីសំគាល់ជាច្រើនទៀត នៅមុខពួកសិស្សទ្រង់ ដែលមិនបានចែងទុកក្នុងសៀវភៅនេះទេ បានចែងទុកតែប៉ុណ្ណោះ ដើម្បីឲ្យអ្នករាល់គ្នាបានជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះពិត ហើយឲ្យអ្នករាល់គ្នាបានជីវិត ដោយសារព្រះនាមទ្រង់ ដោយមានសេចក្តីជំនឿ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# ការអនុវត្ត

ចូរជឿលើព្រះយេស៊ូវ នោះលោកអ្នកនឹងមានជីវិតថ្មី។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# កិច្ចការ

## អ្នកនិពន្ធ
ប្រពៃណីក្រុមជំនុំដំបូងបានសន្មតថា លោក លូកា ដែលមានមុខងារ ជាគ្រូពេទ្យ គឺជាអ្នកនិពន្ធ (កូល៉ុស ៤:១៤, ២ធីម៉ូថេ ៤:១១)។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៦៣ នៃគ.ស។

## ការសង្ខេប
ការយាងមកដល់នៃព្រះវិញ្ញាណបរិសុទ្ធបណ្ដាលឲ្យក្រុមជំនុំរីកចម្រើន មិនថាសាសន៍យូដា ឬសាសន៍ដទៃនោះទេ។

## គម្រោងកណ្ឌគម្ពីរ
I. សាវ័ក ពេត្រុស និងការធ្វើបេសកកម្មចំពោះអ៊ីស្រាអែល
 ជំពូក ១-១២
II. សាវ័ក ប៉ុល និងការធ្វើបេសកកម្មចំពោះសាសន៍ដទៃ
 ជំពូក ១៣-២៨

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
កិច្ចការ ២:៣៨ «ពេត្រុសឆ្លើយតបថា ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឲ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៊ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

កិច្ចការ ៤:១២ “ហើយគ្មានសេចក្ដីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ”។

## ការអនុវត្ត

ចូរប្រែចិត្ត ហើយទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូវ “នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ” (កិច្ចការ ២:៣៨)។

## រូបភាព




ព្រះវិហាររបស់ព្រះសេយូស - កិច្ចការ ១៤:១៣




ព្រះវិហាររបស់ព្រះឌីអាន - កិច្ចការ ១៩:២៤



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# រ៉ូម

## អ្នកនិពន្ធ

សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ រ៉ូម ១:១ បានចែងថា "សំបុត្រប៉ុលខ្ញុំ..." ប៉ុន្តែលោក ទើទាស គឺជាអ្នកកត់ត្រា (រ៉ូម ១៦:២២)។

## ឆ្នាំនិពន្ធ

ប្រហែលក្នុងឆ្នាំ ៥៧ នៃគ.ស ពេលនិទាឃរដូវចាប់ផ្តើម។

## ការសង្ខេប

មនុស្សមានបាបអាចទទួលបានសេចក្តីសង្គ្រោះដោយគ្រាន់តែជឿលើព្រះយេស៊ូវដ៏សុចរិតតែមួយគត់។

## គម្រោងកណ្ឌគម្ពីរ

I. ការបញ្ចេញឲ្យដឹងពីភាពសុចរិតនៃព្រះជាម្ចាស់ ជំពូក ១-៨
II. ការជំនុំជម្រះដ៏សុចរិតរបស់ព្រះជាម្ចាស់ ជំពូក ៩-១១
III. ការអនុវត្តភាពសុចរិតរបស់ព្រះជាម្ចាស់ ជំពូក ១២-១៦



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

រ៉ូម ៣:២១-២៣ «ប៉ុន្តែ ឥឡូវនេះ ក្រៅពីក្រឹត្យវិន័យ សេចក្តីសុចរិតផង ព្រះដែលមានទាំងក្រឹត្យវិន័យ នឹងពួកហោរាធ្វើបន្ទាល់ឲ្យផង នោះ បានលេចចេញមកហើយ គឺជាសេចក្តីសុចរិតរបស់ព្រះ ដែលបាន ដោយសារសេចក្តីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទ ក៏សំរាប់គ្រប់អស់ អ្នកណាដែលជឿផង ដ្បិតគ្មានខុសអំពីគ្នាទេ ពីព្រោះគ្រប់គ្នាបានធ្វើ បាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ»។

រ៉ូម ៨:២៦-៣០ «ព្រះវិញ្ញាណទ្រង់ក៏ជួយសេចក្តីកំសោយរបស់ យើងបែបដូច្នោះដែរ ដ្បិតយើងមិនដឹងជាគួរអធិស្ឋានសូមអ្វីទេ តែ ព្រះវិញ្ញាណទ្រង់ជួយអង្វរជំនួសយើង ដោយដំងូរដែលរកថ្លែងពុំបាន វិញ ប៉ុន្តែ ព្រះអង្គដែលស្ទង់ចិត្ត ទ្រង់ជ្រាបនូវគំនិតនៃព្រះវិញ្ញាណ ដ្បិត ព្រះវិញ្ញាណជួយអង្វរជួសពួកបរិសុទ្ធ ឲ្យត្រូវនឹងព្រះហឫទ័យព្រះ តែ យើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្តីល្អដល់ពួកអ្នកដែល ស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមក តាមព្រះដំរិះទ្រង់ ដ្បិត អ្នកណាដែលទ្រង់បានស្គាល់ជាមុន នោះទ្រង់ក៏តម្រូវទុកជាមុន ឲ្យ បានត្រឡប់ដូចជារូបអង្គនៃព្រះរាជបុត្រាទ្រង់ ដើម្បីឲ្យព្រះរាជបុត្រាបាន ធ្វើជាបងច្បងគេក្នុងពួកបងប្អូនជាច្រើន ឯពួកអ្នកដែលទ្រង់បានតម្រូវ ទុកជាមុន នោះទ្រង់ក៏ហៅ ហើយពួកអ្នកដែលទ្រង់បានហៅ នោះទ្រង់ ក៏រាប់ទុកជាសុចរិត ហើយពួកអ្នកដែលទ្រង់បានរាប់ជាសុចរិត នោះ ទ្រង់ក៏បានដំកើងឡើងដែរ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

រ៉ូម ១២:១-២, ៩-១៣ «ដូច្នេះ បងប្អូនអើយ ខ្ញុំទូន្មានអ្នករាល់គ្នា ដោយសេចក្ដីមេត្តាករុណានៃព្រះ ឲ្យបានថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ជាការគោរពនៃអ្នករាល់គ្នា ដែលមានទំនង កុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ ដោយគំនិតបានកែជាថ្មីឡើង ដើម្បីនឹងអាចលមើលឲ្យបានស្គាល់បំណងព្រះហឫទ័យនៃព្រះ ដែលល្អស្រួលទទួល ហើយគ្រប់លក្ខណ៍ផង…ចូរឲ្យមានសេចក្ដីស្រឡាញ់ឥតពុតមាយា ទាំងខ្ពើមសេចក្ដីអាក្រក់ ហើយកាន់ខ្ជាប់ខាងសេចក្ដីល្អវិញ ខាងឯសេចក្ដីស្រឡាញ់ជាបងជាប្អូន នោះចូរមានចិត្តថ្នមគ្នាទៅវិញទៅមកចុះ ខាងឯសេចក្ដីរាប់អាន នោះឲ្យខំរាប់អានគេជាមុន ខាងឯសេចក្ដីឧស្សាហ៍ នោះកុំឲ្យខ្ជិលឡើយ ខាងឯវិញ្ញាណ នោះក៏ចូរព្យាយាមចុះ ដោយខំប្រឹងបំរើព្រះអម្ចាស់ ចូរអរសប្បាយ ដោយមានសង្ឃឹម ចូរអត់ធន់ក្នុងសេចក្ដីទុក្ខលំបាក ចូរឲ្យខ្ជាប់ខ្ជួនក្នុងសេចក្ដីអធិស្ឋាន ខាងសេចក្ដីខ្វះខាតរបស់ពួកបរិសុទ្ធ នោះក៏ចូរផ្គត់ផ្គង់ឲ្យ ទាំងខំប្រឹងឲ្យមានសេចក្ដីចៅរ៉ៅផងចុះ»។

## ការអនុវត្ត

ចូរជឿលើព្រះយេស៊ូវ នោះព្រះជាម្ចាស់នឹងរាប់លោកអ្នកជាមនុស្សសុចរិត។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៊ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# កូរិនថូស ទី១

## អ្នកនិពន្ធ

សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ប៉ុន្តែលោក សូស្ថេន ជាអ្នកកត់ត្រា (១កូរិនថូស ១:១)។

## ឆ្នាំនិពន្ធ

ប្រហែលក្នុងឆ្នាំ ៥៥ នៃគ.ស។

## ការសង្ខេប

សាវ័ក ប៉ុល ជួយដោះស្រាយបញ្ហាអំពើបាបនៅក្នុងក្រុមជំនុំកូរិនថូស។

## គម្រោងកណ្ឌគម្ពីរ

I. កង្វល់នៅក្នុងក្រុមជំនុំ ជំពូក ១-៤

II. ការកាត់ទោសក្រុមជំនុំ ជំពូក ៥-៦

III. ការផ្តល់យោបល់ដល់ក្រុមជំនុំ ជំពូក ៧-១៦

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

១កូរិនថូស ១:១៨ «ដ្បិតដំណឹងពីឈើឆ្កាង នោះជាសេចក្តីចំកួតដល់អស់អ្នកដែលកំពុងតែវិនាស តែជាព្រះចេស្តានៃព្រះដល់យើងរាល់គ្នាដែលកំពុងតែបានសង្គ្រោះវិញ»។

១កូរិនថូស ១០:៣១ «ដូច្នេះ ទោះបើស៊ី ឬផឹក ឬធ្វើការអ្វីក៏ដោយ នោះចូរធ្វើទាំងអស់សំរាប់ចំរើនសិរីល្អដល់ព្រះចុះ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

១កូរិនថូស ១៣:៤-៧ “ឯសេចក្ដីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្ដីស្រឡាញ់មិនចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស មិនដែលអរសប្បាយចំពោះសេចក្ដីទុច្ចរិតឡើយ គឺអរសប្បាយតែនឹងសេចក្ដីស្មោះត្រង់វិញ ក៏គ្របបាំងទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់”។

១កូរិនថូស ១៦:១៣-១៤ “ចូរចាំយាម ចូរឈរឲ្យមាំមួនក្នុងសេចក្ដីជំនឿ ចូរប្រព្រឹត្តឲ្យពេញជាភាពបុរស ចូរឲ្យមានកំឡាំងចុះ ត្រូវឲ្យអ្នករាល់គ្នាធ្វើការទាំងអស់ ដោយសេចក្ដីស្រឡាញ់”។

**ការអនុវត្ត**

ទោះបីជាក្រុមជំនុំមានបញ្ហាជាច្រើនក៏ដោយ នេះមិនមែនជារឿថ្មីទេ ដូច្នេះចូរស្រឡាញ់គ្នាទៅវិញទៅមក (១កូរិនថូស ១៣)។

## រូបភាព





ភ្លួងជ័យ - ១កូរិនថូស ៩:២៥



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# កូរិនថូស ទី២

## អ្នកនិពន្ធ
សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ប៉ុន្តែលោក ធីម៉ូថេ ជាអ្នកកត់ត្រា (២កូរិនថូស ១:១)។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ៥៥-៥៦ នៃគ.ស។

## ការសង្ខេប
សាវ័ក ប៉ុល ការពារព័ន្ធកិច្ចរបស់គាត់។

## គម្រោងកណ្ឌគម្ពីរ
I. ការពន្យល់ពីព័ន្ធកិច្ចរបស់សាវ័ក ប៉ុល ជំពូក ១-៧

II. សាវ័ក ប៉ុល រៃតង្វាយសម្រាប់ពួកបរិសុទ្ធ ជំពូក ៨-៩

III. សាវ័ក ប៉ុល ការពារព័ន្ធកិច្ចរបស់គាត់ ជំពូក ១០-១៣

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
២កូរិនថូស ៥:១៥, ២១ «ទ្រង់ក៏បានសុគតជំនួសមនុស្សទាំងអស់យ៉ាងនោះ គឺដើម្បីឲ្យពួកអ្នកដែលរស់នៅ មិនរស់សំរាប់តែខ្លួនឯងទៀត គឺរស់សំរាប់ព្រះអង្គ ដែលសុគតជំនួសគេ ហើយបានរស់ឡើងនោះវិញ...ដ្បិតឯព្រះអង្គដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៊ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

២កូរិនថូស ១២:៩ «តែទ្រង់មានបន្ទូលមកខ្ញុំថា គុណរបស់អញល្មម ដល់ឯងហើយ ដ្បិតកំឡាំងអញបានពេញខ្នាត ដោយសេចក្តីកំសោយ ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្តីកំសោយរបស់ខ្ញុំដោយអំណរជាខ្លាំង ដើម្បី ឲ្យព្រះចេស្តានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ»។

២កូរិនថូស ១៣:៥, ១១ «ចូរអ្នករាល់គ្នាពិចារណាខ្លួនឯងមើល តើ ស្ថិតនៅក្នុងសេចក្តីជំនឿឬទេ ចូរល្បងខ្លួនមើលចុះ តើអ្នករាល់គ្នាមិន យល់ឃើញថា ព្រះយេស៊ូវគ្រីស្ទគង់ក្នុងអ្នករាល់គ្នាទេឬអី លើកតែ អ្នករាល់គ្នាត្រូវកាត់ចោលចេញប៉ុណ្ណោះ...ឯសេចក្តីឯទៀត បងប្អូន អើយ ចូរមានសេចក្តីអំណរ ចូរឲ្យបានគ្រប់លក្ខណ៍ ចូរឲ្យមានចិត្ត ក្សេមក្សាន្ត ចូរមានគំនិតដូចគ្នា ចូរនៅដោយមេត្រីនឹងគ្នាចុះ នោះព្រះ នៃសេចក្តីស្រឡាញ់ នឹងសេចក្តីសុខសាន្ត ទ្រង់នឹងគង់នៅជាមួយនឹង អ្នករាល់គ្នា»។

## ការអនុវត្ត

ចូរគោរព ហើយការពារអ្នកដឹកនាំរបស់លោកអ្នក។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# កាឡាទី

## អ្នកនិពន្ធ
សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ កាឡាទី ១:១ បានចែងថា «សំបុត្រប៉ុលខ្ញុំ...»។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៤៩ នៃគ.ស។

## ការសង្ខេប
ព្រះជាម្ចាស់រាប់យើងជាសុចរិត ដោយសារជំនឿរបស់យើងលើព្រះយេស៊ូវ។

## គម្រោងកណ្ឌគម្ពីរ
I. ជីវប្រវត្តិ ជំពូក ១-២

II. ការបង្រៀន ជំពូក ៣-៤

III. ការអនុវត្ត ជំពូក ៥-៦

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
កាឡាទី ៥:២២-២៣ «តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺ សេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត គ្មានក្រឹត្យវិន័យណាទាស់នឹងសេចក្តីយ៉ាងនោះទេ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ដោយសារលោកអ្នកមិនស្ថិតនៅក្រោមក្រឹត្យវិន័យ នោះចូរពឹងលើព្រះវិញ្ញាណបរិសុទ្ធឲ្យជួយរក្សាភាពបរិសុទ្ធក្នុងជីវិតរស់នៅរបស់លោកអ្នក។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# អេភេសូរ

## អ្នកនិពន្ធ
សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ អេភេសូរ ១:១ បានចែង ថា «សំបុត្រប៉ុលខ្ញុំ...»។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៦១ នៃគ.ស។

## ការសង្ខេប
គ្រីស្ទបរិស័ទ គឺជាអវយវៈនៃរូបកាយរបស់ព្រះគ្រីស្ទ។

## គម្រោងកណ្ឌគម្ពីរ
I. ស្ថានភាពនៃគ្រីស្ទបរិស័ទ ជំពូក ១-៣

II. ការអនុវត្តសម្រាប់គ្រីស្ទបរិស័ទ ជំពូក ៤-៦

## សំណេរីខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
អេភេសូរ ៤:១-៦ «ដូច្នេះ ខ្ញុំជាអ្នកជាប់គុកក្នុងព្រះអម្ចាស់ ខ្ញុំទូន្មានអ្នករាល់គ្នាថា ចូរឲ្យអ្នករាល់គ្នាដើរបែបគួរនឹងការងារ ដែលទ្រង់បានហៅមកធ្វើចុះ ព្រមទាំងមានចិត្តសុភាព ហើយស្លូតបូតគ្រប់ជំពូកទាំងអត់ធ្មត់ ហើយទ្រាំទ្រគ្នាទៅវិញទៅមក ដោយស្រឡាញ់ ហើយខំប្រឹងរក្សាសេចក្ដីរួបរួមគ្នារបស់ព្រះវិញ្ញាណ ដោយសេចក្ដីមេត្រី ទុកជាចំណងផង មានរូបកាយតែ១ ហើយព្រះវិញ្ញាណតែ១ ដូចជាទ្រង់បានហៅអ្នករាល់គ្នាមក ក្នុងសេចក្ដីសង្ឃឹមតែ១របស់ការងារអ្នករាល់គ្នាដែរ មានព្រះអម្ចាស់តែ១ សេចក្ដីជំនឿតែ១ បុណ្យជ្រមុជតែ១ មានព្រះ



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

តែ១ គឺជាព្រះវរបិតានៃទាំងអស់ ដែលទ្រង់ខ្ពស់លើទាំងអស់ គង់នៅកណ្តាលទាំងអស់ ហើយសណ្ឋិតនៅក្នុងទាំងអស់»។

អេភេសូរ ៦:១០-២០ «ឯសេចក្តីឯទៀត បងប្អូនអើយ ចូរឲ្យមានកំឡាំងឡើងក្នុងព្រះអម្ចាស់ ដោយឫទ្ធិបារមីរបស់ព្រះចេស្តាទ្រង់ ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអាចនឹងឈរមាំមួន ទាស់នឹងឧបាយកលទាំងអម្បាលម៉ានរបស់អារក្ស ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺនិងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកីយ៍នេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដែរ ហេតុនោះបានជាត្រូវឲ្យយកគ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទប់ទល់ក្នុងថ្ងៃអាក្រក់បាន រួចកាលណាបានតតាំងសព្វគ្រប់ហើយ នោះឲ្យបាននៅតែឈរមាំមួនដដែល ដូច្នេះ ចូរឲ្យឈរមាំមួនចុះ ដោយក្រវាត់សេចក្តីពិតនៅចង្កេះ ហើយពាក់សេចក្តីសុចរិតទុកជាប្រដាប់បាំងដើមទ្រូង ទាំងពាក់សេចក្តីប្រុងប្រៀបរបស់ដំណឹងល្អនៃសេចក្តីសុខសាន្តទុកជាស្បែកជើង ថែមទាំងយកសេចក្តីជំនឿទុកជាខែលផង ដែលអ្នករាល់គ្នានឹងអាចរំលត់ អស់ទាំងព្រួញឆេះរបស់មេកំណាច ដោយសារខែលនោះបាន ចូរយកសេចក្តីសង្គ្រោះទុកជាមួកសឹកនិងដាវរបស់ព្រះវិញ្ញាណដែរ គឺជាព្រះបន្ទូល ព្រមទាំងប្រើសេចក្តីអធិស្ឋាននិងសេចក្តីទូលអង្វរគ្រប់យ៉ាង ដើម្បីអធិស្ឋាន ដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា ហើយចាំយាមក្នុងសេចក្តីនោះឯង ដោយនូវគ្រប់ទាំងសេចក្តីខ្ជាប់ខ្ជួន និងសេចក្តីទូលអង្វរឲ្យពួកបរិសុទ្ធទាំងអស់ ហើយឲ្យខ្ញុំផង ប្រយោជន៍ឲ្យព្រះបានប្រទានពាក្យសំដីមកខ្ញុំ ឲ្យខ្ញុំបាន



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

បើកមាត់ដោយក្លាហាន នឹងសំដែងពីសេចក្ដីអាថ៌កំបាំងនៃដំណឹងល្អ ដែលខ្ញុំជាទូតជាប់ច្រវាក់ ដោយព្រោះដំណឹងល្អនោះឯង ដើម្បីឲ្យខ្ញុំមានសេចក្ដីក្លាហានក្នុងដំណឹងល្អ ប្រយោជន៍ឲ្យខ្ញុំបាននិយាយ តាមដែលគួរគប្បី»។

## ការអនុវត្ត

គ្រីស្ទបរិស័ទគួរប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយក្ដីស្រឡាញ់ ពីព្រោះយើងគឺជាអវយវៈនៃរូបកាយរបស់ព្រះគ្រីស្ទ។

## រូបភាព



គ្រឿងសឹករបស់ព្រះ - អេភេសូរ ៦:១១



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូ | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ភីលីព

## អ្នកនិពន្ធ

សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ប៉ុន្តែលោក ធីម៉ូថេ ជាអ្នកកត់ត្រា (ភីលីព ១:១)។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៦១-៦៣ នៃគ.ស។

## ការសង្ខេប

កណ្ឌគម្ពីរភីលីពរៀបរាប់អំពីអំណរ និងសាមគ្គីភាព។

## គម្រោងកណ្ឌគម្ពីរ

I. ការរងទុក្ខលំបាក ជំពូក ១

II. ការចុះចូល ជំពូក ២

III. ការសង្គ្រោះ ជំពូក ៣

IV. ការញែកជាបរិសុទ្ធ ជំពូក ៤

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ភីលីព ២:១-១១ “ដូច្នេះ បើសិនជាមានសេចក្ដីដាស់តឿនណា ក្នុងព្រះគ្រីស្ទ ឬសេចក្ដីកំសាន្តណារបស់ផងសេចក្ដីស្រឡាញ់ ឬសេចក្ដីប្រកបណាផងព្រះវិញ្ញាណ ឬសេចក្ដីថ្មិតថ្នម និង សេចក្ដីអាណិតអាសូរណា នោះចូរបំពេញសេចក្ដីអំណររបស់ខ្ញុំ ដោយ អ្នករាល់គ្នាមានគំនិត មានសេចក្ដីស្រឡាញ់តែ១ ទាំងរួបរួមចិត្តគ្នា ហើយគិតតែផ្លូវ១ដូចគ្នាចុះ កុំឲ្យធ្វើអ្វី ដោយទាស់ទែងគ្នា ឬដោយ



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

សេចក្ដីអំនួតឥតប្រយោជន៍ឡើយ តែចូររាប់អានគេឲ្យលើសជាងខ្លួន ដោយចិត្តសុភាពវិញ កុំឲ្យគ្រប់គ្នាស្វែងរកតែប្រយោជន៍ផ្ទាល់ខ្លួន ឡើយ ត្រូវស្វែងរកចំពោះអ្នកដទៃផង ត្រូវតែមានគំនិតគិតដូចជា ព្រះគ្រីស្ទយេស៊ូវវិញ ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់ តែមិនបានរាប់សេចក្ដីដែលស្មើនឹងព្រះនោះ ទុកជាសេចក្ដីដែលគួរ កាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជា បាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង ហើយដែល ឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំង ចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់លើ ឈើឆ្កាងផង ដោយហេតុនោះបានជាព្រះបានលើកទ្រង់ឡើងយ៉ាង ខ្ពស់ ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរ លើសជាងអស់ទាំង នាមផង ដើម្បីកាលណាឮព្រះនាមព្រះយេស៊ូវ នោះឲ្យគ្រប់ទាំងជង្គង់ នៅស្ថានសួគ៌ នៅផែនដី ហើយនៅក្រោមផែនដីត្រូវលុតចុះ ហើយឲ្យ គ្រប់ទាំងអណ្តាតបានថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះអម្ចាស់ សំរាប់ជាសិរីល្អដល់ព្រះដ៏ជាព្រះវរបិតា»។

ភីលីព ៤:៨ «មួយទៀត បងប្អូនអើយ ឯសេចក្តីណាដែលពិត សេចក្តី ណាដែលគួររាប់អាន សេចក្តីណាដែលសុចរិត សេចក្តីណាដែល បរិសុទ្ធ សេចក្តីណាដែលគួរស្រឡាញ់ សេចក្តីណាដែលមានឈ្មោះ ល្អ បើមានសគុណណា ឬជាសេចក្តីសរសើរណា នោះចូរពិចារណាពី សេចក្តីទាំងនោះចុះ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

កុំឲ្យស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន ហើយកុំឲ្យមានអំនួត ពីព្រោះការទាំងពីរនេះអាចនាំឲ្យមានការបាក់បែក។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# កូល៉ុស

## អ្នកនិពន្ធ

សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ កូល៉ុស ១:១ បានថែង ថា «សំបុត្រប៉ុលខ្ញុំ...»។

## ឆ្នាំនិពន្ធ

ប្រហែលក្នុងឆ្នាំ ៦១ នៃគ.ស។

## ការសង្ខេប

ព្រះយេស៊ូវគ្រីស្ទមានភាពឧដុង្គឧត្តមខ្ពស់ជាងទស្សនវិជ្ជារបស់ មនុស្ស។

## គម្រោងកណ្ឌគម្ពីរ

I. ភាពគ្រប់គ្រាន់នៃព្រះយេស៊ូវ ជំពូក ១-២

II. ការចុះចូលចំពោះព្រះយេស៊ូវ ជំពូក ៣-៤

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

កូល៉ុស ៤:២ «ចូរព្យាយាមក្នុងសេចក្តីអធិស្ឋាន ទាំងចាំយាមក្នុង សេចក្តីនោះឯង ដោយពាក្យអរព្រះគុណ»។

## ការអនុវត្ត

ចូរឲ្យជីវិតរបស់លោកអ្នកចុះចូលចំពោះព្រះយេស៊ូវទាំងស្រុងដោយ «...ស្វែងរកអស់ទាំងសេចក្តី ដែលនៅស្ថានលើវិញ ជាស្ថានដែល ព្រះគ្រីស្ទគង់នៅខាងស្តាំនៃព្រះ» (កូល៉ុស ៣:១)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ថែស្សាឡូនីច ទី១

## អ្នកនិពន្ធ
សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ប៉ុន្តែលោក ស៊ីសវ៉ាន និងលោក ធីម៉ូថេ ជាអ្នកកត់ត្រា (១ថែស្សាឡូនីច ១:១)។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៥១ នៃគ.ស។

## ការសង្ខេប
ព្រះយេស៊ូវនឹងយាងមកវិញ ដើម្បីទទួលយកអ្នកដើរតាមទ្រង់ទៅនៅជាមួយទ្រង់។

## គម្រោងកណ្ឌគម្ពីរ
I. បទពិសោធន៍ផ្ទាល់ខ្លួន ជំពូក ១-៣

II. ការរំឭកដាស់តឿនឲ្យអនុវត្ត ជំពូក ៤-៥

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
១ថែស្សាឡូនីច ៤:៤-៨ “ត្រូវឲ្យអ្នករាល់គ្នានីមួយៗចេះរក្សាអត្តភាពខ្លួន ដោយសេចក្ដីបរិសុទ្ធ និងសេចក្ដីប្រសើរ មិនមែនដោយសេចក្ដីរំជួលក្នុងតណ្ហា ដូចជាសាសន៍ដទៃដែលមិនស្គាល់ព្រះនោះឡើយ កុំឲ្យអ្នកណាបំពាន ឬធ្វើខុសនឹងបងប្អូនណាមួយក្នុងការនោះឲ្យសោះ ពីព្រោះព្រះអម្ចាស់ទ្រង់នឹងសងសឹកក្នុងការទាំងនោះ ដូចជាយើងខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាហើយ ព្រមទាំងធ្វើបន្ទាល់សព្វគ្រប់ផង ដ្បិតព្រះមិនបានហៅយើងរាល់គ្នា មកក្នុងសេចក្ដីស្មោកគ្រោកទេ



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូ៊ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

គឺមកក្នុងសេចក្ដីបរិសុទ្ធវិញ ដូច្នេះ អ្នកណាដែលមិនព្រមទទួល នោះមិនមែនបោះបង់ចោលមនុស្ស ឈ្មោះថាបោះបង់ចោលព្រះវិញ ដែលទ្រង់បានប្រទានព្រះវិញ្ញាណបរិសុទ្ធនៃទ្រង់មកយើង»។

១ថែស្សាឡូនីច ៥:១៦-២២ «ចូរអរសប្បាយជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណក្នុងគ្រប់ការទាំងអស់ ពីព្រោះព្រះទ្រង់សព្វព្រះហឫទ័យឲ្យអ្នករាល់គ្នាធ្វើយ៉ាងដូច្នោះ ដោយនូវព្រះគ្រីស្ទយេស៊ូវ កុំឲ្យពន្លត់ព្រះវិញ្ញាណ កុំឲ្យមើលងាយការអធិប្បាយឡើយ ចូរលមើលគ្រប់ទាំងអស់ ហើយកាន់ខ្ជាប់តាមសេចក្ដីដែលត្រឹមត្រូវ ចូរចៀសចេញពីសេចក្ដីអាក្រក់គ្រប់យ៉ាង»។

## ការអនុវត្ត

ចូររក្សាភាពបរិសុទ្ធក្នុងជីវិតរស់នៅរបស់លោកអ្នក «ដ្បិតព្រះទ្រង់សព្វព្រះហឫទ័យ...» (១ថែស្សាឡូនីច ៤:៣)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# ថែស្សាឡូនីច ទី២

## អ្នកនិពន្ធ
សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ប៉ុន្តែលោក ស៊ីសវ៉ាន និងលោក ធីម៉ូថេ ជាអ្នកកត់ត្រា (២ថែស្សាឡូនីច ១:១)។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៥១ នៃគ.ស។

## ការសង្ខេប
គ្រីស្ទបរិស័ទត្រូវតែបន្តធ្វើការរហូតដល់ថ្ងៃនៃព្រះយេស៊ូវយាងមកវិញ។

## គម្រោងកណ្ឋគម្ពីរ
I. ការលើកទឹកចិត្តទាក់ទងនឹងការបៀតបៀន ជំពូក ១
II. ការពន្យល់ពីថ្ងៃនៃព្រះអម្ចាស់ ជំពូក ២
III. ការរំឭកដាស់តឿនឲ្យរង់ចាំការយាងមកវិញ
 របស់ព្រះយេស៊ូវ ជំពូក ៣

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
២ថែស្សាឡូនីច ២:១៦-១៧ «សូមឲ្យព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង និងព្រះដ៏ជាព្រះវរបិតា ដែលទ្រង់បានស្រឡាញ់យើង ព្រមទាំងប្រទានឲ្យមានសេចក្តីកំសាន្តអស់កល្បជានិច្ច និងសេចក្តីសង្ឃឹមយ៉ាងល្អ ដោយព្រះគុណទ្រង់ បានកំសាន្តចិត្តអ្នករាល់គ្នាដែរ ហើយតាំងឲ្យអ្នករាល់គ្នាបានមាំមួនឡើង ក្នុងគ្រប់ទាំងការ និងពាក្យសំដីដ៏ល្អផង»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

២ថែស្សាឡូនីច ៣:១៦ «សូមឲ្យព្រះអម្ចាស់ ដែលទ្រង់ផ្តល់សេចក្តីសុខសាន្ត ទ្រង់ប្រទានឲ្យអ្នករាល់គ្នាបានសេចក្តីសុខសាន្តគ្រប់យ៉ាងជានិច្ច សូមឲ្យព្រះអម្ចាស់គង់ជាមួយនឹងអ្នករាល់គ្នាទាំងអស់»។

## ការអនុវត្ត

ចូរទន្ទឹងរង់ចាំការយាងមកវិញរបស់ព្រះយេស៊ូវដោយធ្វើការងាររបស់លោកអ្នកឲ្យអស់ពីចិត្ត ដើម្បីថ្វាយសិរីល្អដល់ទ្រង់ ហើយ «...កុំឲ្យរសាយចិត្តខាងឯការល្អឡើយ» (២ថែស្សាឡូនីច ៣:១៣)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ធីម៉ូថេ ទី១

## អ្នកនិពន្ធ
សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ១ធីម៉ូថេ ១:១ បានចែងថា «សំបុត្រប៉ុលខ្ញុំ...»។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៦៣ នៃគ.ស។

## ការសង្ខេប
កណ្ឌគម្ពីរធីម៉ូថេបង្រៀនគ្រូគង្វាលពីរបៀបនៃការរស់នៅ និងការដឹកនាំក្រុមជំនុំ។

## គម្រោងកណ្ឌគម្ពីរ
I. សេចក្ដីបង្រៀនសម្រាប់លោក ធីម៉ូថេ ផ្ទាល់ខ្លួន ជំពូក ១-៣
II. សេចក្ដីបង្រៀនសម្រាប់គ្រូគង្វាល ជំពូក ៤-៥

## សំណេរីខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
១ធីម៉ូថេ ៣:១៥-១៦ «ដើម្បីក្រែងខ្ញុំក្រមក នោះឲ្យអ្នកបានដឹងពីរបៀបយ៉ាងណា ដែលគួរប្រព្រឹត្តក្នុងដំណាក់នៃព្រះ គឺក្នុងពួកជំនុំនៃព្រះដ៏មានព្រះជន្មរស់ ដែលជាសសរ ហើយជាជើងថ្កល់របស់សេចក្ដីពិត ពិតប្រាកដជាសេចក្ដីអាថ៌កំបាំងរបស់សាសនានៃយើងនោះជ្រាលជ្រៅណាស់គឺដែលព្រះបានលេចមកក្នុងសាច់ឈាម បានរាប់ជាសុចរិតដោយព្រះវិញ្ញាណ ពួកទេវតាបានឃើញទ្រង់ មនុស្សបានប្រកាសប្រាប់ពីទ្រង់ដល់ពួកសាសន៍ដទៃ មានគេជឿដល់ទ្រង់ក្នុងលោកីយ៍នេះ



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប្វា៉ | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

រួចព្រះបានលើកទ្រង់ឡើងទៅក្នុងសិរីល្អវិញ»។

១ធីម៉ូថេ ៦:២០ «ឱធីម៉ូថេអើយ ចូររក្សាសេចក្ដីដែលបានផ្ញើទុកនឹងអ្នកចុះ ហើយចៀសចេញពីសំដីឡេះឡោះឥតប្រយោជន៍ និងពាក្យទទឹងទទែងនៃសេចក្ដី ដែលក្លែងហៅថា ចំណេះវិជ្ជាផង»។

## ការអនុវត្ត

ចូរសិក្សាកណ្ឌគម្ពីរធីម៉ូថេស្ដីពីរបៀបនៃការរស់នៅ និងការដឹកនាំក្រុមជំនុំ ពីព្រោះអ្នកដឹកនាំដ៏ល្អ គឺជាអ្នកដែលមានចរិតលក្ខណៈដែលស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# ធីម៉ូថេ ទី២

## អ្នកនិពន្ធ
សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ២ធីម៉ូថេ ១:១ បានចែងថា «សំបុត្រប៉ុលខ្ញុំ...»។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ៦៦-៦៨ នៃគ.ស។

## ការសង្ខេប
ពាក្យសម្តីចុងក្រោយរបស់សាវ័ក ប៉ុល ទៅកាន់ធីម៉ូថេដែលជាកូនស្ងួនភ្ងា ស្តីពីការរក្សាទុកដំណឹងល្អ ហើយទ្រាំទ្រដើម្បីដំណឹងល្អ។

## គម្រោងកណ្ឌគម្ពីរ
I. សេចក្តីផ្តើមសម្រាប់ការតយុទ្ធខាងឯវិញ្ញាណ ជំពូក ១-៣
II. សេចក្តីបង្គាប់ឲ្យតយុទ្ធខាងឯវិញ្ញាណ ជំពូក ៤

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
២ធីម៉ូថេ ៣:១៦-១៧ «គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះសំរាប់នឹងធ្វើការល្អគ្រប់មុខ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ក្នុងជីវិតរស់នៅរបស់លោកអ្នក តើលោកអ្នកហ៊ានថា៖ «ខ្ញុំបានតយុទ្ធយ៉ាងល្អ ខ្ញុំបានរត់ប្រណាំងជាស្រេច ខ្ញុំបានរក្សាសេចក្ដីជំនឿទៅហើយ» ដូចសាវ័ក ប៉ុល ដែរឬទេ? (២ធីម៉ូថេ ៤:៧)



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៊ូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# ទីតុស

## អ្នកនិពន្ធ

សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ទីតុស ១:១ បានចែងថា «សំបុត្រប៉ុលខ្ញុំ...»។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៦៣-៦៥ នៃគ.ស។

## ការសង្ខេប

កណ្ឌគម្ពីរទីតុសបង្រៀនអ្នកដឹកនាំពីជំនឿ និងការប្រព្រឹត្តក្នុងការរស់នៅ ព្រមទាំងដាស់តឿនពួកគេឲ្យចេះប្រុងប្រយ័ត្នចំពោះគ្រូក្លែងក្លាយ។

## គម្រោងកណ្ឌគម្ពីរ

I. ចាស់ទុំ និងអ្នកធ្វើឲ្យអន់ចិត្ត ជំពូក ១-២

II. ការលើកទឹកចិត្តឲ្យរស់នៅជាគំរូ ជំពូក ៣

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ទីតុស ៣:៥-៧ «នោះទ្រង់បានជួយសង្គ្រោះយើង មិនមែនដោយការដែលយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្តីមេត្តាករុណារបស់ទ្រង់វិញ ដោយសារការសំអាតនៃសេចក្តីកើតជាថ្មី ហើយការប្រោសជាថ្មីឡើងវិញ នៃព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានចាក់មកលើយើងជាបរិបូរ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើង ដើម្បីកាលណាយើងបានរាប់ជាសុចរិត



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

ដោយសារព្រះគុណទ្រង់ នោះឲ្យយើងបានត្រឡប់ជាអ្នកគ្រងមរដក តាមសេចក្តីសង្ឃឹមដល់ជីវិតដ៏នៅអស់កល្បជានិច្ច»។

## ការអនុវត្ត

«ចូររំឭកគេ ឲ្យចុះចូលនឹងពួកនាម៉ឺន ហើយនិងពួកមានអំណាចទាំងអស់ ព្រមទាំងស្តាប់បង្គាប់ ហើយប្រុងប្រៀបធ្វើគ្រប់ទាំងការល្អ មិនត្រូវនិយាយអាក្រក់ពីអ្នកណា ឬឈ្លោះប្រកែកឡើយ ត្រូវមានចិត្តស្លូតបូត ទាំងសំដែងសេចក្តីសុភាពគ្រប់យ៉ាង ដល់មនុស្សទាំងអស់ផង» (ទីតុស ៣:១-២)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ភីលេម៉ូន

## អ្នកនិពន្ធ

សាវ័ក ប៉ុល គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ភីលេម៉ូន ១:១ បានចែង ថា «សំបុត្រប៉ុលខ្ញុំ...»។

## ឆ្នាំនិពន្ធ

ប្រហែលក្នុងឆ្នាំ ៦៣ នៃគ.ស។

## ការសង្ខេប

សាវ័ក ប៉ុល ស្នើសុំភីលេម៉ូនឲ្យទទួលយកអូនេស៊ីមទុកដូចជាប្អូន ស្ងួនភ្ងា (ខ១៦)។

## គម្រោងកណ្ឌគម្ពីរ

I. ការអធិស្ឋាន ខ១-៧

II. ការស្នើសុំ ខ៨-១៦

III. ការសន្យា ខ១៧-២៥

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ខ៤-៥ «ខ្ញុំអរព្រះគុណដល់ព្រះនៃខ្ញុំ ទាំងដំណាលពីអ្នកជានិច្ច ក្នុង កាលដែលខ្ញុំអធិស្ឋានផង ដោយបានឮនិយាយពីសេចក្តីស្រឡាញ់ និងសេចក្តីជំនឿ ដែលអ្នកមានដល់ព្រះអម្ចាស់យេស៊ូវ ហើយដល់ ពួកបរិសុទ្ធទាំងអស់គ្នាដែរ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរអត់ទោសដល់អស់អ្នកដែលធ្វើខុសចំពោះលោកអ្នក ដូចដែលព្រះជាម្ចាស់បានអត់ទោសដល់លោកអ្នកដែរ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# ហេព្រើរ

## អ្នកនិពន្ធ
ព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ
ប្រហែលមុនឆ្នាំ ៧០ នៃគ.ស។

## ការសង្ខេប
ព្រះយេស៊ូវទ្រង់ល្អលើសមនុស្ស និងអ្វីៗទាំងអស់។

## គម្រោងកណ្ឌគម្ពីរ
I. ភាពដ៏ឧដុង្គឧត្តមនៃព្រះយេស៊ូវ ជំពូក ១:១-១០:១៨
II. ភាពដ៏ឧដុង្គឧត្តមនៃការរស់នៅរបស់គ្រីស្ទបរិស័ទ
ជំពូក ១០:១៩-១៣:១-២៥

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
ហេព្រើរ ១០:២៥ «ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំទ្បាចិត្តគ្នាវិញ ឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ»។

ហេព្រើរ ១១:១-២ «រីឯសេចក្តីជំនឿ នោះគឺជាចិត្តដែលដឹងជាក់ថានឹងបានដូចសង្ឃឹម ជាសំគាល់ពីការដែលមើលមិនឃើញ ព្រះទ្រង់បានធ្វើបន្ទាល់ពីមនុស្សចាស់បុរាណ ដោយព្រោះគេមានសេចក្តីជំនឿនោះឯង»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

ហេព្រើរ ១២:១-២ «ដូច្នេះ ដែលមានស្មរបន្ទាល់១ហ្វូងធំម្ល៉េះ នៅព័ទ្ធជុំវិញយើង នោះត្រូវឲ្យយើងចោលអស់ទាំងបន្ទុកនិងអំពើបាបដែលរុំយើងជុំវិញជាងាយម្ល៉េះនោះចេញ ហើយត្រូវរត់ក្នុងទីប្រណាំងដែលនៅមុខយើង ដោយអំណត់ ទាំងរំពឹងមើលដល់ព្រះយេស៊ូវដ៏ជាមេផ្តើម ហើយជាមេសំរេចសេចក្តីជំនឿរបស់យើង ដែលទ្រង់បានរងទ្រាំនៅឈើឆ្កាង ទាំងមើលងាយចំពោះសេចក្តីអាម៉ាស់ខ្មាសនោះឲ្យតែបានសេចក្តីអំណរដែលនៅចំពោះទ្រង់ រួចទ្រង់ក៏គង់ខាងស្តាំបល្ល័ង្កនៃព្រះ»។

## ការអនុវត្ត

ចូរចូលទៅក្នុងបល្ល័ង្កនៃព្រះគុណដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយឲ្យរកបានព្រះគុណនៅពេលដែលលោកអ្នកមានតម្រូវការ (ហេព្រើរ ៤:១៦)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

# យ៉ាកុប

## អ្នកនិពន្ធ

សាវ័ក យ៉ាកុប គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ យ៉ាកុប ១:១ បាន ចែងថា «សំបុត្រយ៉ាកុប...»។

## ឆ្នាំនិពន្ធ

ប្រហែលក្នុងឆ្នាំ ៤៥ នៃគ.ស។

## ការសង្ខេប

ជំនឿដ៏ពិតប្រាកដគឺត្រូវមានការអនុវត្តជាក់ស្ដែង។

## គម្រោងកណ្ឌគម្ពីរ

I. សាសនាដែលបរិសុទ្ធហើយឥតសៅហ្មង ជំពូក ១

II. ជំនឿដ៏ពិតប្រាកដ ជំពូក ២:១-៣:១២

III. ប្រាជ្ញាដ៏ពិតមកពីព្រះជាម្ចាស់ ជំពូក ៣:១៣-៥:២០

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

យ៉ាកុប ១:១៩-២០, ២៧ «ដូច្នេះ បងប្អូនស្ងួនភ្ងាអើយ ចូរឲ្យគ្រប់គ្នាបានឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹងដែរ ដ្បិតសេចក្ដីកំហឹងរបស់មនុស្ស មិនដែលសំរេចតាមសេចក្ដីសុចរិតរបស់ព្រះទេ...ឯសាសនាដែលបរិសុទ្ធ ហើយឥតសៅហ្មង នៅចំពោះព្រះដ៏ជាព្រះវរបិតា នោះគឺឲ្យទៅសួរពួកកំព្រា និងពួកមេម៉ាយ ក្នុងកាលដែលគេមានសេចក្ដីវេទនា ហើយឲ្យរក្សាខ្លួន មិនឲ្យប្រឡាក់ដោយលោកីយ៍នេះឡើយ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹង ដ្បិតកំហឹងរបស់មនុស្សមិនអាចសម្រេចសេចក្តីសុចរិតរបស់ព្រះជាម្ចាស់បានទេ (យ៉ាកុប ១:១៩-២០)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

# ពេត្រុស ទី១

## អ្នកនិពន្ធ

សាវ័ក ពេត្រុស គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ១ពេត្រុស ១:១ បាន ចែងថា «សំបុត្រពេត្រុស...»។

## ឆ្នាំនិពន្ធ

ប្រហែលក្នុងឆ្នាំ ៦៥ នៃគ.ស។

## ការសង្ខេប

ការរងទុក្ខដើម្បីព្រះយេស៊ូវ នោះគឺជាការល្អ។

## គម្រោងកណ្ឌគម្ពីរ

I. សេចក្ដីសង្គ្រោះសម្រាប់អ្នកជឿ ជំពូក ១:១-២:១២
II. ការចុះចូលរបស់អ្នកជឿ ជំពូក ២:១៣-៣:១២
III. ការរងទុក្ខរបស់អ្នកជឿ ជំពូក ៣:១៣-៥:១៤

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

១ពេត្រុស ៥:៦-១១ «ដូច្នេះ ចូរឲ្យអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះចុះ ដើម្បីឲ្យទ្រង់បានដំកើងអ្នករាល់គ្នាឡើង នៅវេលាកំណត់ ហើយចូរផ្ទេរគ្រប់ទាំងសេចក្ដីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា ចូរឲ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន ចូរតស៊ូនឹង



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

វា ដោយមានចិត្តជឿមាំមួន ទាំងដឹងថា ពួកបងប្អូនរបស់អ្នករាល់គ្នា ដែលនៅក្នុងលោកីយ៍នេះ គេកំពុងតែរងទុក្ខលំបាកដូចគ្នាដែរ រីឯព្រះ ដ៏មានព្រះគុណសព្វគ្រប់ ដែលទ្រង់បានហៅយើងរាល់គ្នា មកក្នុង សិរីល្អនៃទ្រង់ ដ៏នៅកល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ នោះសូមទ្រង់ មេត្តាប្រោសឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ ទាំងចំរើនកំឡាំង ហើយ តាំងអ្នករាល់គ្នាឲ្យមាំមួនឡើង ក្នុងខណៈក្រោយដែលបានរងទុក្ខ បន្តិច សូមឲ្យទ្រង់បានសិរីល្អ និងព្រះចេស្តា នៅអស់កល្បជានិច្ច ជា រៀងរាបតទៅ អាម៉ែន»។

## ការអនុវត្ត

ចូររស់នៅដោយមានភាពបរិសុទ្ធ ខណៈពេលដែលយើងរង់ចាំ ការយាងមកវិញរបស់ព្រះយេស៊ូវ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# ពេត្រុស ទី២

## អ្នកនិពន្ធ
សាវ័ក ពេត្រុស គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ ២ពេត្រុស ១:១ បានចែងថា «សំបុត្រស៊ីម៉ូន-ពេត្រុស...»។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៦៦ នៃគ.ស។

## ការសង្ខេប
ចូរប្រុងមើលហើយប្រយ័ត្ននឹងពួកគ្រូក្លែងក្លាយ។

## គម្រោងកណ្ឌគម្ពីរ
I. ភាពបរិសុទ្ធ ជំពូក ១
II. សេចក្ដីបង្រៀនដែលមិនត្រឹមត្រូវ ជំពូក ២
III. សេចក្ដីសង្ឃឹម ជំពូក ៣

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
២ពេត្រុស ២:១-៣ «តែកាលពីដើម មានហោរាក្លែងក្លាយ នៅក្នុងពួកជន ដូចជានឹងមានគ្រូក្លែងក្លាយក្នុងពួកអ្នករាល់គ្នាដែរ គេនឹងលួចនាំបញ្ចូលបក្សពួកដែលបង្ខូចបំផ្លាញ គេមិនព្រមស្គាល់ព្រះដ៏ជាម្ចាស់ដែលបានលោះគេនោះឡើយ ក៏នាំសេចក្ដីវិនាសដ៏ឆាប់រហ័សឲ្យមកលើខ្លួនផង នឹងមានមនុស្សជាច្រើនទៅតាមផ្លូវវិនាសរបស់គេ នោះផ្លូវពិតនឹងត្រូវសេចក្ដីប្រមាថមើលងាយ ដោយព្រោះគេដែរ ហើយដោយគេមានចិត្តលោភ នោះគេនឹងប្រើអ្នករាល់គ្នាឲ្យបានចំណេញ ដោយ



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

ពោលពាក្យបញ្ឆោតបំពោត តែតាំងពីយូរមកហើយ សេចក្តីជំនុំជំរះគេ
មិននៅស្ងៀមស្ងាត់ទេ ហើយសេចក្តីហិនវិនាសរបស់គេក៏មិនងុយងោក
ដែរ»។

## ការអនុវត្ត

«...ពួកស្ងួនភ្ងាអើយ ចូរប្រយ័ត្ន ដោយព្រោះអ្នករាល់គ្នាដឹងសេចក្តីនោះ
ជាមុនហើយ ក្រែងលោធ្លាក់ពីសេចក្តីខ្ជាប់ខ្ជួនរបស់អ្នករាល់គ្នាចេញ
ដោយបណ្តោយតាមសេចក្តីវង្វេងរបស់ពួកទទឹងច្បាប់នោះ» ដូច្នេះចូរ
ចាំយាមចុះ ដ្បិតព្រះយេស៊ូវជិតយាងមកវិញហើយ
(២ពេត្រុស ៣:១៧)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៉ូវ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# យ៉ូហាន ទី១

## អ្នកនិពន្ធ

ប្រពៃណីក្រុមជំនុំដំបូងបានសន្មតថាសាវ័ក យ៉ូហាន គឺជាអ្នកនិពន្ធ ប៉ុន្តែព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៨៥-៩០ នៃគ.ស។

## ការសង្ខេប

សាវ័ក យ៉ូហាន អះអាងពីសេចក្តីពិតដែលផ្តល់ជីវិតអស់កល្បជានិច្ច ដល់អ្នកជឿ។

## គម្រោងកណ្ឌគម្ពីរ

I. សេចក្តីផ្តើមនៃជីវិតអស់កល្បជានិច្ច ជំពូក ១:១-៤
II. ស្ថានភាពនៃជីវិតអស់កល្បជានិច្ច ជំពូក ១:៥-២:២
III. លក្ខណៈនៃជីវិតអស់កល្បជានិច្ច ជំពូក ២:៣-៤:១២
IV. លទ្ធផលនៃជីវិតអស់កល្បជានិច្ច ជំពូក ៥

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

១យ៉ូហាន ១:៩-១០ «បើយើងលន់តួបាបវិញ នោះទ្រង់មាន ព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យ យើង ហើយនឹងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង បើយើង ថា យើងមិនដែលធ្វើបាបសោះ នោះឈ្មោះថាយើងធ្វើឲ្យទ្រង់ទៅជា អ្នកកុហកវិញ ហើយព្រះបន្ទូលទ្រង់មិននៅក្នុងយើងទេ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៊ូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រៈ *http://cambodianchristianresources.com/bib*

១យ៉ូហាន ៣:១៣-១៤ «បងប្អូនអើយ បើលោកីយ៍ស្អប់អ្នករាល់គ្នា នោះកុំឲ្យឆ្ងល់ឡើយ យើងរាល់គ្នាដឹងថា យើងបានកន្លងផុតពីសេចក្តីស្លាប់ ទៅដល់ជីវិតហើយ ពីព្រោះយើងស្រឡាញ់ដល់ពួកបងប្អូន ឯអ្នកណាដែលមិនស្រឡាញ់បងប្អូន អ្នកនោះជាអ្នកនៅជាប់ក្នុងសេចក្តីស្លាប់នៅឡើយ»។

១យ៉ូហាន ៥:១៣-១៥ «ខ្ញុំបានសរសេរសេចក្តីទាំងនេះ ផ្ញើមកអ្នករាល់គ្នា ដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ យើងក៏មានសេចក្តីក្លាហាន ដល់ទ្រង់យ៉ាងដូច្នេះដែរ គឺថា បើយើងនឹងសូមអ្វី ដែលត្រូវតាមព្រះហឫទ័យទ្រង់ នោះទ្រង់នឹងទទួលព្រម បើយើងដឹងថា ទ្រង់ទទួលព្រមតាមយើង ក្នុងការអ្វីដែលយើងសូមដូច្នេះ នោះយើងក៏ដឹងថា យើងបានអ្វីដែលយើងសូមពីទ្រង់ហើយដែរ»។

## ការអនុវត្ត

តើលោកអ្នកពិតជាដឹងថា លោកអ្នកបានទទួលសេចក្តីសង្គ្រោះរួចហើយ? ចូរកត់សម្គាល់អត្តចរិតរបស់អ្នកជឿដ៏ពិតនៅក្នុងកណ្ឌគម្ពីរនេះ។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# យ៉ូហាន ទី២

## អ្នកនិពន្ធ

ប្រពៃណីក្រុមជំនុំដំបូងបានសន្មតថា សាវ័ក យ៉ូហាន គឺជាអ្នកនិពន្ធ ប៉ុន្តែព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៨៥-៩០ នៃគ.ស។

## ការសង្ខេប

ចូរប្រុងមើលហើយប្រយ័ត្ននឹងពួកគ្រូក្លែងក្លាយដែលមិនព្រមទទួលស្គាល់ថាព្រះយេស៊ូវមានរូបកាយ។

## គម្រោងកណ្ឌគម្ពីរ

I. ចូរនៅជាប់នឹងបញ្ញត្តិព្រះជាម្ចាស់ ខ១-៦

II. កុំឲ្យនៅជាប់នឹងពួកគ្រូក្លែងក្លាយ ខ៧-១៣

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ខ៨-៩ «ត្រូវឲ្យអ្នករាល់គ្នាប្រយ័ត្ន ក្រែងបាត់ផលការដែលបានធ្វើហើយនោះ គឺឲ្យបានទទួលរង្វាន់ដ៏ពេញលេញវិញ អ្នកណាដែលប្រព្រឹត្តរំលង ហើយមិនកាន់ខ្ជាប់ ក្នុងសេចក្ដីបង្រៀនរបស់ព្រះគ្រីស្ទ អ្នកនោះជាអ្នកគ្មានព្រះទេ តែអ្នកណាដែលកាន់ខ្ជាប់ ក្នុងសេចក្ដីបង្រៀនរបស់ព្រះគ្រីស្ទវិញ អ្នកនោះមានទាំងព្រះវរបិតា និងព្រះរាជបុត្រាផង»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

កុំឲ្យទទួល ឬជំរាបសួរអ្នកណាដែលមិនបង្រៀនថា ព្រះយេស៊ូវគ្រីស្ទ បានមកក្នុងសាច់ឈាមឡើយ (ខ១០-១១)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# យ៉ូហាន ទី៣

## អ្នកនិពន្ធ

ប្រពៃណីក្រុមជំនុំដំបូងបានសន្មតថាសាវ័ក យ៉ូហាន គឺជាអ្នកនិពន្ធ ប៉ុន្តែព្រះគម្ពីរមិនបានចែងថាអ្នកណាជាអ្នកនិពន្ធនោះទេ។

## ឆ្នាំនិពន្ធ

នៅក្នុងអំឡុងឆ្នាំ ៨៥-៩០ នៃគ.ស។

## ការសង្ខេប

សាវ័ក យ៉ូហាន សរសើរហើយលើកទឹកចិត្តកៃយុស ប៉ុន្តែព្រមាន ឌីអូត្រេព។

## គម្រោងកណ្ឌគម្ពីរ

I. ភាពជាអ្នកបម្រើ ខ១-៨

II. ការទាស់ទែងគ្នា ខ៩-១៥

## សំណេរខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់

ខ១១ "អ្នកស្ងួនភ្ងាអើយ ចូរត្រាប់តាមសេចក្ដីល្អ កុំឲ្យតាមសេចក្ដីអាក្រក់ឲ្យសោះ អ្នកណាដែលប្រព្រឹត្តល្អ នោះមកពីព្រះ តែអ្នកណាដែលប្រព្រឹត្តអាក្រក់ នោះមិនបានឃើញព្រះឡើយ"។

## ការអនុវត្ត

ចូរត្រាប់តាមសេចក្ដីល្អ ហើយគេចចេញពីសេចក្ដីអាក្រក់ (ខ១១)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# យូដាស

## អ្នកនិពន្ធ
សាវ័ក យូដាស គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ យូដាស ១:១ បាន ចែងថា “សំបុត្រយូដាស...”។

## ឆ្នាំនិពន្ធ
នៅក្នុងអំឡុងឆ្នាំ ៦៧-៦៨ នៃគ.ស។

## ការសង្ខេប
ចូរប្រុងមើលហើយប្រយ័ត្ននឹងពួកគ្រូក្លែងក្លាយ និងសេចក្តីបង្រៀន របស់ពួកគេដែលបណ្តាលឲ្យមានគ្រោះថ្នាក់។

## គម្រោងកណ្ឌគម្ពីរ
I. គោលបំណងនៃសំបុត្រ ខ១-៣
II. របៀបរស់នៅរបស់ពួកគ្រូក្លែងក្លាយ ខ៤-១៦
III. ការអនុវត្តសម្រាប់អ្នកជឿ ខ១៧-២៥

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
ខ២០-២៣ “ប៉ុន្តែ ឯអ្នករាល់គ្នា ជាពួកស្ងួនភ្ងាអើយ ចូររក្សាខ្លួនក្នុង សេចក្តីស្រឡាញ់របស់ព្រះចុះ ព្រមទាំងរង់ចាំសេចក្តីមេត្តាករុណារបស់ ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ឲ្យបានជីវិតអស់កល្បជានិច្ច វិញ ដោយស្អាងចិត្តឡើងក្នុងសេចក្តីជំនឿដ៏បរិសុទ្ធបំផុតរបស់ អ្នករាល់គ្នា ហើយទាំងអធិស្ឋាន ដោយនូវព្រះវិញ្ញាណបរិសុទ្ធផង ចូរ មានចិត្តអាណិតដល់ពួកអ្នកខ្លះ ដែលមានសេចក្តីសង្ស័យផង ហើយ


រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

ជួយសង្គ្រោះដល់អ្នកដទៃ ទាំងឆក់យកគេចេញពីភ្លើង ហើយត្រូវមាន
ចិត្តមេត្តាដល់មនុស្សឯទៀត ដោយភ័យខ្លាច ហើយស្អប់ដល់ទាំងអាវ
ដែលត្រូវស្មោកគ្រោក ដោយសាច់ឈាមផង»។

## ការអនុវត្ត

ចូរខំតយុទ្ធ ដើម្បីការពារជំនឿដែលព្រះជាម្ចាស់បានប្រគល់ដល់
លោកអ្នក (ខ៣)។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

# វិវរណៈ

## អ្នកនិពន្ធ
សាវ័ក យ៉ូហាន គឺជាអ្នកនិពន្ធ ពីព្រោះកណ្ឌគម្ពីរ វិវរណៈ ១:១ បានចែងថា «...ទ្រង់ក៏បានសម្ដែងឲ្យឃើញ ដោយចាត់ទេវតាទ្រង់មកឯយ៉ូហានជាបាវបំរើទ្រង់»។

## ឆ្នាំនិពន្ធ
ប្រហែលក្នុងឆ្នាំ ៩៥ នៃគ.ស។

## ការសង្ខេប
«...ដើម្បីនឹងបង្ហាញដល់ពួកបាវបំរើទ្រង់ឲ្យដឹងពីអស់ទាំងការដែលបន្តិចទៀតត្រូវកើតមានមក...» (វិវរណៈ ១:១)។

## គម្រោងកណ្ឌគម្ពីរ
I. ការឃើញព្រឹត្តិការណ៍ ជំពូក ១
II. ព្រឹត្តិការណ៍ដែលកំពុងកើតឡើង ជំពូក ២-៣
III. ព្រឹត្តិការណ៍ដែលនឹងកើតឡើង ជំពូក ៤-២២

## សំណើខគម្ពីរសម្រាប់ការសញ្ជឹងគិត និងការទន្ទេញចាំមាត់
វិវរណៈ ១:៣ «មានពរហើយ អ្នកណាដែលមើល និងអស់អ្នកដែលស្តាប់ពាក្យទំនាយទាំងនេះ ហើយប្រព្រឹត្តតាមសេចក្តីទាំងប៉ុន្មាន ដែលកត់ទុកនេះដែរ ដ្បិតឯពេលវេលា នោះជិតដល់ហើយ»។


រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង ប៊ូ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*

វិវរណៈ ៤:១១ «ឱព្រះអម្ចាស់ ជាព្រះនៃយើងរាល់គ្នាអើយ ទ្រង់គួរនឹងទទួលសិរីល្អ កិត្តិនាម និងព្រះចេស្តា ដ្បិតទ្រង់បានបង្កើតរបស់សព្វសារពើមក ហើយគឺដោយបំណងព្រះហឫទ័យទ្រង់ហើយ ដែលរបស់ទាំងនោះបានកើតមក ហើយមាននៅផង»។

វិវរណៈ ៥:១៣ «នោះខ្ញុំក៏ឮគ្រប់ទាំងអស់ ដែលមានជីវិត នៅស្ថានសួគ៌ នៅផែនដី នៅក្រោមដី ហើយនៅក្នុងសមុទ្រ និងគ្រប់ទាំងអស់ដែលនៅស្ថានទាំងនោះនិយាយថា សូមថ្វាយព្រះពរ កិត្តិនាម សិរីល្អ និងព្រះចេស្តា ដល់ព្រះអង្គដែលគង់លើបល្ល័ង្ក ហើយដល់កូនចៀម នៅអស់កល្បជានិច្ចរៀងរាបតទៅ»។

វិវរណៈ ២១:៤ «ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ និងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទួញ ឬទុក្ខលំបាកណាទៀតឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មាន បានកន្លងបាត់ទៅហើយ»។

វិវរណៈ ២២:១៨-១៩ «ខ្ញុំធ្វើបន្ទាល់ ដល់អស់អ្នកណា ដែលឮសេចក្តីទំនាយ ក្នុងគម្ពីរនេះថា បើអ្នកណាបញ្ចូលអ្វីក្នុងសេចក្តីទាំងនេះ នោះព្រះទ្រង់នឹងបន្ថែមអស់ទាំងសេចក្តីវេទនា ដែលកត់ទុកក្នុងគម្ពីរនេះ ដល់អ្នកនោះផង ហើយបើអ្នកណាដកអ្វី ពីព្រះបន្ទូលក្នុងគម្ពីរនៃសេចក្តីទំនាយនេះចេញ នោះព្រះទ្រង់នឹងដកចំណែក ដែលអ្នកនោះមានដល់ដើមជីវិត និងទីក្រុងបរិសុទ្ធ ហើយនិងសេចក្តីទាំងប៉ុន្មានដែលកត់ទុកក្នុងគម្ពីរនេះចេញដែរ»។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ៖ *http://cambodianchristianresources.com/bib*

## ការអនុវត្ត

ចូរទន្ទឹងរង់ចាំការយាងមកវិញជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ពីព្រោះព្រះជាម្ចាស់មានជ័យជម្នះលើគ្រប់វិញ្ញាណអាក្រក់ និងសាតាំង។ អស់អ្នកដែលជឿលើព្រះយេស៊ូវនឹងសោយរាជ្យជាមួយទ្រង់អស់កល្បជានិច្ចនៅផ្ទៃមេឃថ្មី និងផែនដីថ្មី។



រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៤ ដោយ លោក ឈាង បូរ៉ា | v១.០
លោកអ្នកអាចទាញយកសៀវភៅនេះដោយឥតគិតថ្លៃនៅលើគេហទំព័រ *http://cambodianchristianresources.com/bib*